# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ

# ប្រៃសណីយ៍កម្ពុជា ក.អ

ASSETS MANAGEMENT OF CAMBODIA POST BANK PLC.

## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

**រាជធានីភ្នំពេញ-ឆ្នាំ ២០២៤**

PHNOM PENH-2024

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ
# ប្រៃសណីយ៍កម្ពុជា ក.អ

ASSETS MANAGEMENT OF CAMBODIA POST BANK PLC.

## សាស្ត្រាចារ្យណែនាំ ៖ ត្រុង សាវរី

## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

**រាជធានីភ្នំពេញ- ឆ្នាំ ២០២៤**

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**

**ប្រធានបទ៖ ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក. អ**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | សាស្ត្រាចារ្យ គ្រុង សាវរី |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន មជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាហិរញ្ញវត្ថុ និងធនាគារជាពិសេស ក្រុមនាងខ្ញុំយល់ច្បាស់ថាជំនាញហិរញ្ញវត្ថុ និងធនាគារគឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ និងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិត ឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមនាងខ្ញុំ សង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមនាងខ្ញុំ សម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមនាងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមនាងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គង ដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**សុច សុយោន**
ID: B21/517



**ឆន លីសា**
ID: B21/568



**ម៉ិះ ស្រីខេង**
ID: B21/2369



**យ៉ាន់ លាងអ៊ីម**
ID: B21/1198



**ចិត្ត ស៊ីម៉េង**
ID: B21/1240

# **សេចក្ដីថ្លែងអំណរគុណ**

ក្រុមនាងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញហិរញ្ញវត្ថុ និងធនាគារ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមនាងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមនាងខ្ញុំសូមសម្ដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្ដល់កំណើតដល់ពួកខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្ដុះបណ្ដាលក្រុមនាងខ្ញុំនាពេលកន្លងមក។

ក្រុមនាងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្ដល់ទីកន្លែងបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **គ្រុង សាវរី** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមនាងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមនាងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមនាងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និង ធនាគារ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថាខ្លឹមសារសារណាក្រោមប្រធានបទ"ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

បច្ចុប្បន្នវិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាកំពុងមានការរីកចម្រើនយ៉ាងខ្លាំង នៅលើគ្រប់វិស័យជាហេតុ ធ្វើឱ្យមានការកកើតនូវស្ថាប័នហិរញ្ញវត្ថុយ៉ាងសុះសាយពាសពេញផ្ទៃប្រទេស ដែលក្នុងនោះស្ថាប័ននីមួយៗ បានខិតខំពង្រឹង និងបង្កើនសេវាកម្មរៀងៗខ្លួនឱ្យ ដើរទាន់បច្ចេកវិទ្យាទំនើប និងធានាបាននូវការប្រកួតប្រជែងពីសំណាក់ដៃគូរបស់ខ្លួនផង ក៏ដូចជាបំពេញតម្រូវការរបស់អតិថិជនផងដែរ។

ជាក់ស្តែង សម្រាប់ក្រុមនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ ទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសកម្មរបស់ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ដែលក្រុមនាងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវមួយនេះ នឹងបានផ្តល់ជាចំណេះដឹង និងអត្ថប្រយោជន៍មួយចំនួនដល់អ្នកដែលមានបំណងចង់ស្វែងយល់អំពី ធនាគារប្រៃសណីយ៍កម្ពុជា ក.អ។ ក្នុងនោះទៀតសោត ក្រុមនាងខ្ញុំបានស្រាវជ្រាវទាក់ទិនទៅនឹងចំណុចមួយចំនួន ដូចជាប្រវត្តិរបស់ធនាគារ ទស្សនវិស័យ បេសកម្ម រចនាសម្ព័ន្ធរបស់ធនាគារ ក្រុមប្រឹក្សាភិបាល ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ និងសារៈសំខាន់នៃការគ្រប់គ្រងទ្រព្យមូលធនផ្សេងៗ នៅក្នុងធនាគារ ក៏ដូចជាចំនួនដើមទុនរបស់ធនាគារទ្រព្យសកម្ម និងការកើនឡើងនៃទ្រព្យសកម្មរបស់ធនាគារពីមួយឆ្នាំទៅមួយឆ្នាំ ហើយម្យ៉ាងទៀតក្រុមនាងខ្ញុំ បានធ្វើការបញ្ជៀតបន្ថែមនូវលក្ខណៈរបស់សេវានីមួយៗ លក្ខខណ្ឌក្នុងការប្រើប្រាស់នឹងឯកសារតម្រូវមួយចំនួនផងដែរ។

ក្រោយពីបានសិក្សាស្រាវជ្រាវពីការគ្រប់គ្រងទ្រព្យសកម្មរបស់ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ រួចមក ក្រុមនាងខ្ញុំអាចសន្និដ្ឋានបានថា ធនាគារប្រៃសណីយ៍កម្ពុជា ក.អ មានការរីកចម្រើនតាំងពីការកកើតឡើងរហូតមកដល់ពេលបច្ចុប្បន្ន គឺដោយសារតែធនាគារប្រៃសណីយ៍កម្ពុជា ក.អ បានព្យាយាមបង្កើនការគ្រប់គ្រង គិតគូរអំពីហានិភ័យដែលកើតមានជាយថាហេតុ និងស្វែងយល់ពីសារៈសំខាន់នៃការគ្រប់គ្រង ចេះរិះរកនូវគំនិតថ្មីៗ ដើម្បីធ្វើការអភិវឌ្ឍន៍ និងបង្កើនស្នាដៃនៅក្នុងវិស័យធនាគារផងដែរ។ មិនតែប៉ុណ្ណោះ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ បានពង្រីកបណ្តាញការិយាល័យក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនបង្កើតសេវាកម្មីផ្សេងៗផងដែរ។

# មាតិកា


ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធក្រុម ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

**ជំពូកទី១**
**សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី២**
**រំលឹកទ្រឹស្តី**

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងទ្រព្យសកម្ម ........ ៥
    ២.១.១ និយមន័យ ........ ៥
    ២.១.២ ប្រវត្តិនៃការកកើតទ្រព្យសកម្ម ........ ៥
    ២.១.៣ ទ្រឹស្តីទូទៅនៃទ្រព្យសកម្ម ........ ៦
២.២ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារ ........ ៩
    ២.២.១ និយមន័យ ........ ៩
    ២.២.២ ប្រវត្តិនៃការកកើតធនាគារ ........ ៩
    ២.២.៣ តួនាទីរបស់ធនាគារ ........ ១០
    ២.២.៤ មុខងាររបស់ធនាគារ ........ ១១
២.៣ នីតិវិធីនៃការគ្រប់គ្រងទ្រព្យសកម្ម ........ ១៤
    ២.៣.១ និយមន័យ ........ ១៤
    ២.៣.២ ប្រវត្តិទាក់ទងនឹងនីតិ ........ ១៥
    ២.៣.៣ ប្រភេទនៃនីតិ ........ ១៥

២.៤ ផលប្រយោជន៍នៃការគ្រប់គ្រង ........ ១៧

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ១៩
៣.១.១ ប្រវត្តិរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ១៩
៣.១.២ គោលនយោបាយរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២១
៣.១.៣ បេសកកម្ម និងទស្សនវិស័យរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២១
៣.១.៤ និមិត្តសញ្ញា និង អត្តសញ្ញាណរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២២
៣.១.៥ រចនាសម្ព័ន្ធរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២៣
៣.២ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២៤
៣.២.១ ប្រភេទឥណទានរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ២៦
៣.៣ នីតិវិធីនៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឱ្យមានប្រសិទ្ធភាព ........ ២៨
៣.៣.១ លក្ខណៈនៃការគ្រប់គ្រងទ្រព្យសកម្ម ........ ២៩
៣.៣.២ ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសកម្ម ........ ៣០
៣.៤ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ........ ៣០

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣២
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៣៣

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........ ៣៤
៥.២ ការផ្តល់អនុសាសន៍ ........ ៣៤
ឯកសារយោង
ឧបសម្ព័ន្ធ

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន ភាគច្រើនមានប្រព័ន្ធពីរដែលមានលក្ខណៈស្រដៀងគ្នា ដែលប្រព័ន្ធនោះគឺ ប្រព័ន្ធសារពើពន្ធ និងប្រព័ន្ធហិរញ្ញវត្ថុ។ ប្រព័ន្ធសារពើពន្ធ ជាប្រព័ន្ធមួយដែលគ្រប់គ្រងដោយពន្ធដារ ក្នុងការតាមដានចំណូលនិងចំណាយរបស់រដ្ឋាភិបាល។ ចំណែកឯ ប្រព័ន្ធហិរញ្ញវត្ថុជាប្រព័ន្ធមួយដែលមានតួនាទីប្រមូលផ្ដុំមូលនិធិ ឬធនធាន ដែលនៅសេសសល់ក្នុងសេដ្ឋកិច្ច រួចបំបែងមូលនិធិទាំងនោះទៅដល់អ្នកវិនិយោគទាំងឡាយណា ដែលត្រូវការទុនសម្រាប់វិនិយោគ។ ប្រទេសកម្ពុជាក្រោយពីបានទទួលបានឯករាជ្យពីរបបអាណានិគមនិយមបារាំងវិញ នាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មកក៏បានបង្កើតធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ដែលមានតួនាទីបោះពុម្ពរូបិយវត្ថុជាតិគ្រប់គ្រងហិរញ្ញវត្ថុ ហើយពេលនេះប្រព័ន្ធធនាគារក៏មាននៅបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន ភាគច្រើនមានប្រព័ន្ធពីរដែលមានលក្ខណៈស្រដៀងគ្នា ដែលប្រព័ន្ធនោះគឺ ប្រព័ន្ធសារពើពន្ធនិងប្រព័ន្ធហិរញ្ញវត្ថុ។ប្រព័ន្ធសារពើពន្ធជាប្រព័ន្ធមួយដែលកើតឡើងដែលមានធនាគាររដ្ឋនិងធនាគារឯកជនប្រតិបត្តិការទន្ទឹមគ្នានៅលើទឹកដីកម្ពុជា។

ដោយសារការផ្លាស់ប្ដូរមុខមាត់ថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា និងដោយសារតែគោលនយោបាយរបស់ប្រទេសកម្ពុជាមានស្ថេរភាពពេញលេញនោះ បានធ្វើឱ្យវិស័យសេដ្ឋកិច្ចជាតិមានការរីកចម្រើនគួរឱ្យកត់សម្គាល់ជាពិសេស វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ធនាគារ ក្រុមហ៊ុនឯកជន និងការកើនឡើងនៃវិនិយោគិន។ មិនតែប៉ុណ្ណោះភាពរីកចម្រើននៃវិស័យសេដ្ឋកិច្ចគឺមានការចូលរួមយ៉ាងសំខាន់ពីវិស័យធនាគារ និងហិរញ្ញវត្ថុហើយការរីកចម្រើនរបស់វិស័យធនាគារនិងហិរញ្ញវត្ថុ ក៏ព្រោះតែសេដ្ឋកិច្ចកម្ពុជាមានភាពលូតលាស់និងរឹងមាំ។ ដូច្នេះវិស័យទាំងពីរនេះពិតជាមិនអាចខ្វះមួយណាបាននោះឡើយ ហើយគឺជាការបំពេញតម្រូវការគ្នាទៅវិញទៅមក។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ប្រព័ន្ធធនាគារនៅកម្ពុជា រួមមានធនាគារពាណិជ្ជ៥៩ ធនាគារឯកទេស៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ៨២ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ១៧ គ្រឹះស្ថានឥណទានជនបទ២២៣។ វិស័យធនាគារនិងហិរញ្ញវត្ថុបន្តមានភាពធន់និងរឹងមាំ ជាមួយនឹងការថយចុះឥណទានរៀបចំឡើងវិញ និងកម្រិតទាបនៃឥណទានមិនដំណើរការ ដោយសារការបន្តងើបឡើងនិងការវិលទៅរកប្រក្រតីភាពនៃសកម្មភាពសេដ្ឋកិច្ច ស្របពេលដែលការធ្វើប្រក្រតីកម្មឡើងវិញនៃវិធានការគាំទ្រដែលបានដាក់ចេញក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ ត្រូវបានអនុវត្តន៍ជាបណ្ដើរៗ ដើម្បីបន្តពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។

ក្នុងនោះ ការគ្រប់គ្រងទ្រព្យសកម្ម ក៏ជាផ្នែកមួយដ៏សំខាន់របស់ធនាគារសម្រាប់ធានានូវភាពរឹងមាំរបស់ខ្លួននិងដើម្បីការពារហានិភ័យផ្សេងៗដូចជា ការគ្រប់គ្រងសាច់ប្រាក់របស់អតិថិជន ការប្រើប្រាស់សាច់ប្រាក់ឱ្យត្រូវតាមរយៈ ការផ្ដល់ឥណទានដល់អតិថិជនយកទៅប្រើប្រាស់ដើម្បីបង្កើននិងពង្រីកអាជីវកម្ម ឬក្នុងគោលបំណងផ្សេងៗទៀត។ ជាមួយគ្នានេះដែរ ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

ពិតជាមានសារៈសំខាន់ណាស់ ចំពោះធនាគារប្រៃសណីយ៍កម្ពុជា ក.អ ក្នុងការស្វែងរកប្រាក់ចំណេញនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនសំដៅទៅដល់ភាពរីកចម្រើននៃសេដ្ឋកិច្ចនិងសង្គមជាតិទាំងមូល។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

នាសម័យទំនើបភាវូបនីយកម្ម គឺពិតជាពោរពេញទៅដោយការប្រកួតប្រជែងខ្ពស់ទាំង ក្នុងប្រទេស និងក្រៅប្រទេស។ ដូច្នេះ រាល់តម្រូវការ ឬសកម្មភាពការងារទាំងឡាយណាដែលទាក់ទិន គឺតែងតែគិតគូរពីប្រសិទ្ធភាព និងសមិទ្ធផលជាចម្បង។ តាមរយៈបញ្ហានេះ យើងបានលើកសំណួរចំនួនបីមកចោទសួរគឺ៖

១.តើប្រភេទនៃទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ មានអ្វីខ្លះ?

២.តើត្រូវមាននីតិវិធីអ្វីខ្លះ ដើម្បីគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឱ្យមានប្រសិទ្ធភាព?

៣.តើការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់ប្រយោជន៍អ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវគឺសិក្សានិងពិនិត្យមើលពីការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ហើយផ្តោតការស្វែងយល់ទៅលើ៖

- ស្ថានភាពទូទៅរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ
- រក្សានិងគ្រប់គ្រងស្ថេរភាពរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ
- ការគ្រប់គ្រងទ្រព្យសកម្មនិង ការបង្កើនប្រាក់ចំណូលរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ
  + នីតិវិធីគ្រប់គ្រងទ្រព្យសកម្ម
  + ការផ្សព្វផ្សាយទ្រព្យសកម្ម
  + ការបញ្ចេញទ្រព្យសកម្ម
  + ការប្រមូលទ្រព្យសកម្ម
  + នីតិវិធី និងដំណោះស្រាយនៃការគ្រប់គ្រងទ្រព្យសកម្មពេលមានបញ្ហា
  + ទិន្នន័យទ្រព្យសកម្មសរុបរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ក្នុងឆ្នាំ ២០២០
  + ស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយក្នុងការគ្រប់គ្រងទ្រព្យសកម្ម
  + ធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់យោបល់រួមចំពោះធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ដែនកំណត់នៃការស្រាវជ្រាវ

ចំពោះទីតាំងសិក្សាស្រាវជ្រាវ ក្រុមនាងខ្ញុំជ្រើសរើសយកធនាគារប្រៃសណីយ៍កម្ពុជាក.អ ដែលមានអាស័យដ្ឋានស្ថិតនៅក្នុងផ្ទះលេខ១ និង លេខ២ ផ្លូវជាតិលេខ៤ ភូមិបូរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ដើម្បីយកមកធ្វើការសិក្សា ។

### ១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ធនាគារប្រៃសណីយ៍កម្ពុជា ក.អ គឺជាធនាគារមួយដែលបានបើកដំណើរការជាយូរឆ្នាំមកហើយ និងមានសាខាជាច្រើននៅក្នុងប្រទេសហើយ ដោយផ្អែកទៅលើប្រធានបទដែលបានកំណត់ពីខាងដើមនឹងត្រូវ

យកមកសិក្សា វិភាគ និងបកស្រាយក្នុងដែនកំណត់សម្រាប់តែប្រភេទទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ក្នុងឆ្នាំ២០២០តែប៉ុណ្ណោះ ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរ

វិធីសាស្ត្រដែលក្រុមនាងខ្ញុំបានយកមកប្រើប្រាស់ក្នុងការសរសេរមានដូចជា បែបពិពណ៌នា វិភាគ បែបប្រៀបធៀប និង បែបរុករក។

### ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ

- របៀបប្រមូលទិន្នន័យដើម្បីសរសេរមានពីរបែប៖ គឺបែបបរិមាណ និងបែបគុណភាព
- ទិន្នន័យ១៖
+ តាមរយៈការស្រាវជ្រាវពីអ៊ីនធឺណេត
+ តាមការផ្តល់ព័ត៌មានពីអតិថិជនដែលទទួលបាននូវប្រាក់កម្ចី។
- ទិន្នន័យ២៖
+ ប្រមូលតាមរយៈឯកសារដែលមានស្រាប់ពាក់ព័ន្ធនឹងធនាគារនៅក្នុងបណ្ណាល័យ
+ ឯកសារនិងសៀវភៅក្នុងវេបសាយរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ
+ ឯកសារមេរៀនដែលបានសិក្សាកន្លងមក។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទ ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា អ.ក គឺបានស្វែងយល់ពីទ្រឹស្តីនិងបានចុះកម្មសិក្សាដោយផ្ទាល់ជាមួយធនាគារ។ ដូច្នេះការអនុវត្តជាក់ស្តែងបានបង្ហាញនូវចំណេះដឹងដែល បានមកពីការសិក្សាទ្រឹស្តីបទបានជាបទពិសោធន៍ក្នុងការធ្វើនិក្ខេបបទរបស់ក្រុមនាងខ្ញុំ។ ចំពោះប្រធានបទនៃនិក្ខេបបទនេះនឹងផ្តល់ប្រយោជន៍ជាច្រើនដូចខាងក្រោម៖

+ សម្រាប់ស្ថាប័នហិរញ្ញវត្ថុធនាគារប្រៃសណីយ៍កម្ពុជា ក.អ
    - ជាការជួយផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មជូនដល់អតិថិជននិង សាធារណជន
    - លើកឡើងមកនូវគុណវិបត្តិនិង គុណសម្បត្តិនៃដំណើរការប្រតិបត្តិការ
    - បង្កើនភាពជឿជាក់ដល់អតិថិជនលើសេវាកម្មរបស់ស្ថាប័នហិរញ្ញវត្ថុ
    - ជាឯកសារសម្រាប់ផ្សព្វផ្សាយសេវាកម្មរបស់ខ្លួន
    - ចូលរួមផ្តល់អនុសាសន៍មួយចំនួនដែលពាក់ព័ន្ធនឹងចំណុចខ្វះខាត។
+ សម្រាប់អតិថិជន
    - ជាឯកសារជំនួយដល់អតិថិជនបានយល់ដឹងច្បាស់ពីការផ្តល់សេវាកម្មផ្សេងៗ
    - បានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់និងគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ។
+ សម្រាប់សមាជិកស្រាវជ្រាវ
    - ពង្រឹងសមត្ថភាពយល់ដឹងលើផ្នែកទ្រឹស្តីនិងបទពិសោធន៍លើវិស័យធនាគារនិងហិរញ្ញវត្ថុ
    - បង្ហាញនូវសាមគ្គីភាពនិងការសហការគ្នាសម្រាប់សមាជិកស្រាវជ្រាវ
    - បង្កើនឱកាសក្នុងការរកការងារធ្វើ

- មានលទ្ធភាពអាចបញ្ចប់ការសិក្សារបស់ខ្លួនបានយ៉ាងជោគជ័យ
- បានផ្តល់ជាឯកសារសម្រាប់និស្សិតដែលកំពុងធ្វើការសិក្សាស្រាវជ្រាវនិងសម្រាប់និស្សិតជំនាន់ក្រោយៗ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា ៥ ជំពូកដូចខាងក្រោមៈ

ជំពូកទី១ ៖ សេចក្តីផ្តើមៈ ត្រូវបង្ហាញពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្រ្ត ស្រាវជ្រាវ។

ជំពូកទី២ ៖ រំលឹកទ្រឹស្តីៈ ត្រូវលើកឡើងពីទ្រឹស្តីដែលពាក់ព័ន្ធ ទស្សនទាន ឬសំដីរបស់អ្នកប្រាជ្ញ និងបទពិសោធន៍ផ្សេងៗទៀត។

ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវៈ លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាពដូចជា ប្រវត្តិរបស់អង្គភាព បេសកកម្ម ទស្សនវិស័យ គោលនយោបាយ រចនាសម្ព័ន្ធចាត់តាំង (តួនាទី និងភារកិច្ច) និងបន្ទាប់មកត្រូវលើកឡើងឱ្យបានពីរ ឬបីចំណុចទៅលើការងារបច្ចេកទេស របស់អង្គភាព។

ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយៈ វិភាគទៅលើចំណុចទាំងអស់ ដែលបានអនុវត្តជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣) គឺក្នុងគោលបំណង វិភាគអោយឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អ។

ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ៈ ធ្វើការសិន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងទ្រព្យសកម្ម

### ២.១.១ និយមន័យ

**ទ្រព្យសកម្ម** គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យសំដៅទៅលើទ្រព្យសម្បត្តិនានា ជាកម្មសិទ្ធិរបស់ក្រុមប្រឹក្សាដែលមានតម្លៃមួយពិតប្រាកដរួមទាំងប្រាក់កាសផង[1]។

**ទ្រព្យសកម្ម** គឺជាធនធានដែលគ្រប់គ្រងដោយអង្គភាព កើតឡើងដោយសារព្រឹត្តិការណ៍ អតីតកាល និងពីផលប្រយោជន៍សេដ្ឋកិច្ច ដែលរំពឹងទុកថានឹងហូរចូលមកក្នុងសហគ្រាស[2]។

**ទ្រព្យសកម្ម** គឺជាទ្រព្យដែលត្រូវបានប្រើដោយអាជីវកម្មនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ ឬប្រចាំថ្ងៃរបស់ខ្លួន។ ទ្រព្យសកម្មអាចមានលក្ខណៈជាក់ស្តែងដូចជាអគារ ឬ គ្រឿងបរិក្ខា ឬ រូបអរូបី ដូចជា ប៉ាតង់ ឬសិទ្ធិអ្នកនិពន្ធ[3]។

**ទ្រព្យសកម្ម** (ទ្រព្យសកម្ម) សំដៅទៅអតីតកាលដើម្បីនាំយកប្រតិបត្តិការអាជីវកម្ម ឬព្រឹត្តិការណ៍ជាមួយឬបានគ្រប់គ្រងដោយក្រុមហ៊ុននេះត្រូវបានគេរំពឹងថានឹងជាធនធានផលប្រយោជន៍សេដ្ឋកិច្ច[4]។

### ២.១.២ ប្រវត្តិនៃការកើតទ្រព្យសកម្ម

ទ្រព្យសកម្ម ត្រូវបានរាយជាទ្រព្យនៅលើតារាងតុល្យការរបស់អាជីវកម្ម។ ប្រភេទដែលជាចំណុចសំខាន់នៃភាពខុសគ្នានៃទ្រព្យសម្បត្តិគឺ ជាសមត្ថភាពបង្កើតប្រាក់ចំណូល។ ទ្រព្យសកម្មដែលតម្រូវឱ្យរក្សាប្រតិបត្តិការស្តង់ដារខណៈដែលប្រាក់ចំណូលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម។

អាជីវកម្មពឹងផ្អែកទៅលើទ្រព្យសកម្មដើម្បីដំណើរការជារៀងរាល់ថ្ងៃ។ ទ្រព្យសកម្មឈរផ្ទុយទៅនឹងទ្រព្យអសកម្មដែលមិនចាំបាច់សម្រាប់អាជីវកម្ម នៅពេលដែលបានកំណត់ ដើម្បីប្រតិបត្តិការ។ ទ្រព្យសកម្មក៏មិនគួរច្រឡំជាមួយការបែងចែកទ្រព្យសកម្មដែលជាប្រភេទយុទ្ធសាស្ត្រវិនិយោគ។ ទ្រព្យដែលមិនមែនជាមូលដ្ឋាន នៃប្រតិបត្តិការប្រចាំថ្ងៃរបស់អាជីវកម្ម អាចបង្កើតប្រាក់ចំណូលដូចជាមូលបត្ររតនាគារប៉ុន្តែទ្រព្យសម្បត្តិទាំងនេះមិនសកម្មដោយសារតែពួកវាមិនត្រូវបានរក្សាមុខរបរឱ្យដំណើរទៅដោយធម្មតា។ក្រុមអ្នកវិភាគ និងអ្នកគ្រប់គ្រងអាជីវកម្មត្រួតពិនិត្យទ្រព្យសកម្ម ដើម្បីមើលពីការរំខានក្នុងពេលប្រតិបត្តិការអាជីវកម្ម។ បើសិន ទ្រព្យសកម្មមួយចំនួនដែលមានសារៈសំខាន់ ចាំបាច់ចំពោះប្រតិបត្តិការអាជីវកម្ម ប្រចាំថ្ងៃមានការផ្លាស់ប្តូរជាច្រើនវាអាចបង្ហាញពីការខូចខាតក្នុងដំណើរការហិរញ្ញវត្ថុឬប្រតិបត្តិការ។ បច្ចុប្បន្ន ទ្រព្យសកម្ម គឺជាធាតុស្តង់ដារនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យសហគ្រាស។ កម្រិតនិងលក្ខណៈ នៃទ្រព្យសកម្មនឹងផ្លាស់ប្តូរជាមួយនឹងឧស្សាហកម្មផ្សេងៗគ្នា ឬសូម្បីតែក្រុមហ៊ុនអាជីវកម្មជាក់លាក់ដែលមាននីតិវិធីប្រតិបត្តិការខុសៗគ្នា ប៉ុន្តែនឹងក្លាយមកជាឧស្សាហកម្មដូចគ្នា។ ឧទាហរណ៍ អាជីវកម្មពីរដែលលក់ផលិតផលស្រដៀងគ្នានេះតាមអ៊ីនធឺណេតអាចប្រើប្រាស់ ការអនុវត្តន៍ប្រភពធនធានផ្សេងៗគ្នាយ៉ាងទូលំទូលាយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានលើការគ្រប់គ្រងដើមទុន។ នៅទីនេះអាជីវកម្ម មួយអាចដំណើរការ គោលនយោបាយសារពើភ័

[1] https://m.facebook.com/858652100918355/photos/a.930019690448262/1674677989315758/?type=3 (15-Feb-2024)

[2] https://hi-in.facebook.com/MeMongPage/posts/1558024454374090/ (15-Feb-2024)

[3] https://mathnmoney.blogspot.com/2018/09/active-asset.html (15-Feb-2024)

[4] https://km.swewe.net/word_show.htm (25-Feb-2024)

ណ្ឌ ដ៏គួរឱ្យភ្ញាក់ផ្អើលមួយ ខណៈដែលមួយទៀតប្រើរចនាបទអភិរក្ស បន្ថែមដោយរក្សាផលិតផលជាច្រើន នៅលើដៃមិនមានវិធីត្រឹមត្រូវ ឬខុសតែមួយ។ រក្សាកម្រិតទ្រព្យសកម្ម គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់គ្រងធំជាងគេ[5]។

### ២.១.៣ ទ្រឹស្តីទូទៅនៃទ្រព្យសកម្ម

ទ្រព្យសកម្ម គឺជាទ្រព្យដែលត្រូវបានប្រើដោយអាជីវកម្មនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ ឬប្រចាំថ្ងៃរបស់ខ្លួន។ ទ្រព្យសកម្មអាចមានលក្ខណៈជាក់ស្តែងដូចជា អគារឬគ្រឿងបរិក្ខារ ឬរូបអរូបីដូចជាប៉ាតង់ឬសិទ្ធិអ្នកនិពន្ធ។ ទ្រព្យសកម្ម ត្រូវបានរាយជាទ្រព្យនៅលើតារាងតុល្យការរបស់អាជីវកម្ម។ ប្រភេទដែលជាចំណុចសំខាន់នៃភាពខុសគ្នានៃទ្រព្យសម្បត្តិ គឺជាសមត្ថភាពបង្កើតប្រាក់ចំណូល។ ទ្រព្យសកម្ម ដែលតម្រូវឱ្យរក្សាប្រតិបត្តិការស្តង់ដារខណៈដែលប្រាក់ចំណូលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម។ អាជីវកម្មពឹងផ្អែកទៅលើទ្រព្យសកម្មដើម្បីដំណើរការជារៀងរាល់ថ្ងៃ។ ទ្រព្យសកម្ម ឈរផ្ទុយទៅនឹងទ្រព្យអសកម្ម ដែលមិនចាំបាច់សម្រាប់អាជីវកម្មនៅពេលដែលបានកំណត់ដើម្បីប្រតិបត្តិការ។ ទ្រព្យសកម្ម ក៏មិនគួរច្រឡំជាមួយការបែងចែកទ្រព្យសកម្មដែលជាប្រភេទយុទ្ធសាស្ត្រវិនិយោគ។

ទ្រព្យដែលមិនមែនជាមូលដ្ឋាន នៃប្រតិបត្តិការប្រចាំថ្ងៃរបស់អាជីវកម្មអាចបង្កើតប្រាក់ចំណូល ដូចជាមូលបត្ររតនាគារ ប៉ុន្តែទ្រព្យសម្បត្តិទាំងនេះ មិនសកម្មដោយសារតែពួកវាមិនត្រូវបានរក្សាមុខរបរឱ្យដំណើរទៅដោយធម្មតា។ ក្រុមអ្នកវិភាគ និងអ្នកគ្រប់គ្រងអាជីវកម្មត្រួតពិនិត្យទ្រព្យសកម្មដើម្បីមើលពីការរំខានក្នុងពេលប្រតិបត្តិការអាជីវកម្ម។ ប្រសិនបើ ទ្រព្យសកម្មមួយចំនួនដែលមានសារៈសំខាន់ចាំបាច់ចំពោះប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃមានការផ្លាស់ប្តូរជាច្រើន វាអាចបង្ហាញពីការខូចខាតក្នុងដំណើរការហិរញ្ញវត្ថុ ឬប្រតិបត្តិការ។ បច្ចុប្បន្នទ្រព្យសកម្ម គឺជាធាតុស្តង់ដារនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យសហគ្រាស។ កម្រិតនិងលក្ខណៈនៃទ្រព្យសកម្មនឹងផ្លាស់ប្តូរជាមួយនឹងឧស្សាហកម្មផ្សេងៗគ្នា ឬសូម្បីតែក្រុមហ៊ុនអាជីវកម្មជាក់លាក់ដែលមាននីតិវិធីប្រតិបត្តិការខុសៗគ្នាប៉ុន្តែ មកពីឧស្សាហកម្មដូចគ្នា។ឧទាហរណ៍អាជីវកម្មពីរដែលលក់ផលិតផលស្រដៀងគ្នានេះ តាមអ៊ីនធឺណែតដែល អាចប្រើប្រាស់ការអនុវត្តន៍ប្រភពធនធានផ្សេងៗគ្នាយ៉ាងទូលំទូលាយនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានលើការគ្រប់គ្រងដើមទុន។ នៅទីនេះអាជីវកម្មមួយអាចដំណើរការគោលនយោបាយសារពើភ័ណ្ឌដ៏គួរឱ្យភ្ញាក់ផ្អើលមួយខណៈ ដែលមួយទៀតប្រើរចនាបទអភិរក្សបន្ថែមដោយរក្សាផលិតផលជាច្រើននៅលើដៃ។ មិនមានវិធីត្រឹមត្រូវ ឬខុសតែមួយ។ រក្សាកម្រិតទ្រព្យសកម្ម គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់គ្រងធំជាងគេ[6]។

ទ្រព្យសកម្មរបស់ធនាគារមានដូចខាងក្រោម៖

**ក.** សាច់ប្រាក់និងបំណុលពីស្ថាប័នប្រាក់បញ្ញើ( Cash and Due from Depository Institutions ) ខ្ទង់ដំបូងបំផុតនៃទ្រព្យសកម្ម ដែលបានចុះនៅក្នុងរបាយការណ៍ស្ថានភាព របស់ធនាគារ គឺសាច់ប្រាក់និងប្រាក់បញ្ញើនៅធនាគារដទៃទៀត។ ខ្ទង់នេះរួមមាន សាច់ប្រាក់នៅក្នុងឃ្លាំងប្រាក់ ប្រាក់បញ្ញើ ដែលបានដាក់នៅស្ថាប័នប្រាក់បញ្ញើផ្សេងៗ សាច់ប្រាក់ដែលកំពុងប្រមូលក្នុងខ្ទង់ដំបូងបំផុតនៃទ្រព្យសកម្ម ដែលបានចុះនៅក្នុងរបាយការណ៍ស្ថានភាពរបស់ធនាគារ គឺសាច់ប្រាក់និងប្រាក់បញ្ញើនៅធនាគារដទៃទៀត។ ខ្ទង់នេះរួមមាន

[5] https://mathnmoney.blogspot.com/2018/09/active-asset.html (25-Feb-2024)
[6] mathandmoney.com: តើអ្វីទៅជា "ទ្រព្យសកម្ម ឬActive Asset"? (mathnmoney.blogspot.com) (20-Mar-2024)

សាច់ប្រាក់នៅក្នុងឃ្លាំងប្រាក់ ប្រាក់បញ្ញើដែលបានដាក់នៅស្ថាប័នប្រាក់បញ្ញើផ្សេងៗ សាច់ប្រាក់ដែលកំពុងប្រមូល(នៅក្នុងទម្រង់ជាមូលប្បទានបត្រមិនទាន់ទូទាត់) ហើយនិងគណនីប្រាក់បម្រុងរបស់ធនាគារ ដែលមាននៅក្នុងធនាគារប្រាក់បម្រុងសហព័ន្ធ នៅក្នុងតំបន់ដែលគេហៅថាប្រាក់បម្រុងបឋម។ ទ្រព្យសកម្មសាច់ប្រាក់ គឺជាបន្ទាត់ទីមួយរបស់ធនាគារដើម្បីការពារការដកប្រាក់ ហើយជាប្រភពមូលធនដំបូង ដែលធនាគារត្រូវពិនិត្យមើល នៅពេលដែលអតិថិជនមកសុំខ្ចីឥណទានដោយគ្មានការព្រៀងទុក។ ជានិច្ចកាល ការតម្កល់ទុកនេះគឺត្រូវតម្កល់នៅធនាគារកណ្តាល ឬហៅថាធនាគារជាតិ។

**ខ.** ការវិនិយោគមូលបត្រ(Investment Securities)៖ បន្ទាត់ទី២ដែលប្រើប្រាស់ ដើម្បីឆ្លើយតបនឹងតម្រូវការសាច់ប្រាក់ និងបម្រើជាប្រភពមូលធនរបស់ធានាគារ ដែលងាយប្តូរជាសាច់ប្រាក់ ត្រូវបានគេហៅថាប្រាក់បម្រុងទី២។ មូលបត្រទាំងនេះ រួមមានមូលបត្ររដ្ឋាភិបាលរយៈពេលខ្លី និងមូលបត្រឯកជនចេញដោយទីផ្សារមូលបត្រដូចជាមូលបត្រមានការប្រាក់និងពេលកំណត់ និងផលបត្រពាណិជ្ជកម្ម។ ភារកិច្ចរបស់ប្រាក់បម្រុងទី២ គឺជាមូលដ្ឋានកណ្តាលរវាងទ្រព្យសកម្មសាច់ប្រាក់និងឥណទាន ហើយវាក៏ជាការរកចំណូលផងដែរ ប៉ុន្តែវាមានតួនាទីយ៉ាងសំខាន់មួយទៀតនោះ គឺភាពងាយស្រួលដែលត្រូវបានគេប្តូរជាសាច់ប្រាក់ទៅតាមកាលកំណត់រយៈពេលខ្លី។ ក្នុងតារាង ២.២ ប័ណ្ណងាយដូរជាសាច់ប្រាក់ ដែលមានតម្លៃ $8,285 millions ត្រូវបានបង្ហាញជាការវិនិយោគមូលបត្រ ដែលធ្វើប្រតិបត្តិការដោយធនាគារ ដែលនឹងបម្រើជាប្រាក់បម្រុងទី២ ដើម្បី ជួយដោះស្រាយតម្រូវការសន្ទនីយភាព។

**គ.** ការវិនិយោគមូលបត្រចំណូលថេរ សញ្ញាប័ណ្ណ(Bonds) ប័ណ្ណ(Notes) និង មូលបត្រ(Security) ផ្សេងៗ ដែលបានកាន់កាប់ដោយធនាគារសម្រាប់រកចំណូល ដែលគេស្គាល់ថាជាការវិនិយោគលើមូលបត្រ ។ មូលបត្រចែកចេញជាពីរគឺៈ មូលបត្រជាប់ពន្ធ(Taxable securities)៖ មូលបត្រជាប់ពន្ធរួមមាន សញ្ញាបណ្ណ និងបណ្ណរបស់រដ្ឋាភិបាល និងសញ្ញាបណ្ណ និងបណ្ណ របស់ក្រុមហ៊ុនសាជីវកម្ម ។មូលបត្រមិនជាប់ពន្ធ(Tax-exempt securities)៖ មូលបត្រមិនជាប់ពន្ធ រួមមានសញ្ញាប័ណ្ណរបស់រដ្ឋាភិបាលតំបន់ឬមូលដ្ឋាន(USA) ហើយចំណូលដែលបានមកត្រូវរួចពន្ធសហព័ន្ធ។ មូលបត្រវិនិយោគ ត្រូវបានគេកត់ត្រាក្នុងសៀវភៅ ធនាគារតាមតម្លៃដំបូងដែលជាតម្លៃទីផ្សារ ឬក៏តម្លៃទាបជាង ឬមួយតម្លៃទីផ្សារ។ ធនាគារភាគច្រើនកត់ត្រាមូលបត្ររបស់ខ្លួនដែលខ្លួនបានទិញ ហើយទ្រព្យ និងបំណុលផ្សេងទៀតតាមតម្លៃដើម។

**ឃ.** គណនីពាណិជ្ជកម្មទ្រព្យសកម្ម(Trading account assets) មូលបត្រ ដែលបានទិញដើម្បីទទួលបានប្រាក់ចំណេញរយៈពេលខ្លីសម្រាប់ថ្លៃរយៈពេលខ្លី មិនរាប់បញ្ចូលមូលបត្រទាំងនេះនៅក្នុងតារាងតុល្យការទេ។

**ង.** កម្ចីនិងភតិសន្យា(Loans and Leases)៖ ខ្ទង់ទ្រព្យដែលធំជាងគេ គឺកម្ចី និងភតិសន្យា ដែលជាទូទៅគណនីនេះ មានប្រហែលពីពាក់កណ្តាលរហូតដល់៣ភាគ៤(¾) នៃទ្រព្យសកម្មសរុបរបស់ធនាគារ។ គណនីឥណទានរបស់ធនាគារ ត្រូវបានគេបែងចែកជាច្រើនក្រុម ទៅតាមប្រភេទរបស់កម្ចីដែលដូចគ្នា។ នៅក្នុងករណីនេះ សូមមើលតារាងតុល្យការតាមប្រភេទ កម្ចីដូចខាងក្រោមៈ

១- កម្ចីសម្រាប់កិច្ចការជំនួញ និងឧស្សាហកម្ម

២- កម្ចីសម្រាប់កែលម្អនូវជីវភាព និង ការរស់នៅ

៣- កម្ចីសម្រាប់ការជំនួញអចលទ្រព្យ

៤- កម្ចីទៅឱ្យស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត

៥- កម្ចីទៅឱ្យបរទេស ឬ ប្រទេសមួយទៅប្រទេសមួយទៀត

៦- កម្ចីសម្រាប់វិស័យកសិកម្ម

៧- កម្ចីលើផ្នែកមូលបត្រ ដើម្បីបង្កើននូវដើមទុន និង សកម្មភាពរបស់ ក្រុមហ៊ុនឬ សហគ្រាស

៨-ភតិសន្យា៖ ជាធម្មតារួមមាន ការទិញសម្ភារៈបរិក្ខាររបស់ធនាគារ សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងឡាយ ហើយប្រើសម្ភារៈបរិក្ខារទាំងនោះក្នុងកំឡុងពេលជាក់លាក់មួយ ដោយផ្តល់ថ្លៃឈ្នួល ទៅឱ្យធនាគារវិញ។ មានតួលេខឥណទានពីរគឺ ឥណទានដុល និងភតិសន្យា និងឥណទានសុទ្ធ និងភតិសន្យាដែលកើតឡើងនៅក្នុងតារាងតុល្យការរបស់ធនាគារ។ ក្នុងតារាង២.២ ឥណទានដុល និងភតិសន្យាមានចំនួន109,734ដុល្លារ នៅក្នុងឆ្នាំបច្ចុប្បន្ន ឬប្រហែល ៨១ % នៃទ្រព្យសកម្មសរុបរបស់ធានាគារ។

**ច**. ឥណទានបាត់បង់(Loans loses)៖ ឥណទានបាត់បង់ កាត់បន្ថយចំនួនឥណទានសរុប។ ស្ថិតនៅក្រោមច្បាប់របស់សហរដ្ឋអាមេរិក ធនាគារនិងស្ថាប័នទទួលប្រាក់បញ្ញើទាំងឡាយ ត្រូវបានអនុញ្ញាតឱ្យបង្កើតសំវិធានធនសម្រាប់ការបាត់បង់ឥណទាន នៅពេលអនាគតដែលហៅថាការឧបត្ថមធន សម្រាប់ឥណទានបាត់បង់(The allowance for loan losses = ALL)។

**ឆ**. មូលធនសហព័ន្ធដែលលក់ និងមូលប័ត្រដែលទិញក្រោមកិច្ចព្រមព្រៀងលក់វិញ ប្រភេទឥណទានផ្សេងទៀត ដែលបានចុះក្នុងតារាងតុល្យការ គឺមូលធនសហព័ន្ធដែលលក់និងមូលបត្រ ដែលទិញក្រោមកិច្ចព្រមព្រៀងលក់វិញ ខ្ទង់នេះរួមមានឥណទានបណ្តោះអាសន្ន ដែលផ្តល់ឱ្យធនាគារផ្សេងៗ និងពាណិជ្ជករមូលបត្រ។ ខ្ទង់នេះរួមបញ្ចូលនូវកម្ចីសំខាន់ៗ ជាធម្មតាអូសបន្លាយ មួយយប់ដើម្បីការបង្វិលទុនមកសម្រាប់ថ្ងៃបន្ទាប់ធ្វើប្រតិបត្តិទៅនឹងធនាគារមួយទៀត ពាណិជ្ជករ មូលបត្រ ឬសហព័ន្ធសំខាន់ៗដទៃទៀត។

**ជ**. បំណុលអតិថិជនលើប័ណ្ណបំណុលទទួល(Acceptance) ធនាគារធំៗ ជាច្រើនតែងតែផ្តល់ឥណទានដល់អតិថិជនរបស់ខ្លួនក្នុងទម្រង់ ឥណទាន និងទម្រង់ជាហិរញ្ញប្បទានប័ណ្ណបំណុល។ ចំនួនប្រាក់ត្រូវបានគេបង្ហាញនៅក្នុងគណនីទ្រព្យមានឈ្មោះថា បំណុលអតិថិជនមានទម្រង់ជាប័ណ្ណបំណុលរបស់ធនាគារដែលមានឈ្មោះថា ប័ណ្ណបំណុលមិនទាន់ទូទាត់ ។

**ឈ**. កេរ្តិ៍ឈ្មោះជំនួញ និងទ្រព្យសកម្មអរូបិយដទៃទៀត (Goodwill and other intangible assets) កេរ្តិ៍ឈ្មោះជំនួញកើតឡើងនៅពេលដែលក្រុមហ៊ុនមួយ ត្រូវការក្រុមហ៊ុនមួយទៀត ហើយនឹងចំណាយច្រើនជាងតម្លៃទីផ្សាររបស់ទ្រព្យសកម្មពិតរបស់វា(ទ្រព្យសកម្មតិចជាងបំណុល)។ ទ្រព្យសកម្មផ្សេងទៀតរួមមានសិទ្ធិបម្រើសេវាកម្មនិក្ខេប និងការទិញទំនាក់ទំនងប័ណ្ណឥណទាន។

**ញ**. ទ្រព្យសកម្មផ្សេងៗទៀត៖ ទ្រព្យសកម្មរបស់ធនាគាររាប់បញ្ចូលផងដែរ នូវតម្លៃសុទ្ធនៃ អាគារ និងឧបករណ៍ប្រើប្រាស់ក្នុងធនាគារ(បន្ទាប់ពីដករំលស់) ការវិនិយោគលើក្រុមហ៊ុនរណប ការបង់ធានារ៉ាប់រងជាមុន ព្រមទាំងខ្ទង់ទ្រព្យសកម្មសំខាន់ផ្សេងទៀត[7]។

[7] https://khemsarith.wordpress.com/2016/Abank-asset/ (25-Feb-2024)

## ២.២ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារ

### ២.២.១ និយមន័យ

**ធនាគារ** គឺជា ឃ្លាំងដាក់ទ្រព្យ ឃ្លាំងប្រាក់[8]។

**ធនាគារ** គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលប្រាក់បញ្ញើ ដើម្បីដកតាមតម្រូវការ (ដូចជាសរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច) ហើយនឹងផ្តល់ឥណទានទៅឱ្យសាធារណជន និងអាជីវកម្ម (ផ្តល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងហាងរបស់ពួកគេ ឬដើម្បីទិញសម្ភារបរិក្ខារថ្មីៗ)[9]។

**ធនាគារ** គឺជានិតិបុគ្គល ដែលមាន និតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារ ជាមុខរបរប្រក្រតីរបស់ខ្លួន[10]។

**ធនាគារ** គឺជាអន្តរការីហិរញ្ញវត្ថុដែលផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុយ៉ាងទូលំទូលាយជាពិសេសការផ្តល់ឥណទាន ការទទួលប្រាក់បញ្ញើ ការបម្រើសេវាកម្មទូទាត់ និង អនុវត្តន៍នូវមុខងារហិរញ្ញវត្ថុនៃក្រុមហ៊ុនសាជីវកម្ម ក្នុងសេដ្ឋកិច្ច[11]។

### ២.២.២ ប្រវត្តិនៃការកកើតធនាគារ

បច្ចុប្បន្នអ្នកណាក៏ស្គាល់ធនាគារដែរ ហើយប្រហែលជាស្គាល់ច្បាស់ថែមទៀតផង ព្រោះស្ទើរតែគ្រប់គ្នាទៅហើយ ដែលជំពាក់លុយធនាគារ មិនថាខ្ចីយកមករកស៊ី ខ្ចីយកមកសាងសង់ផ្ទះ ខ្ចីយកមកធ្វើស្រែចម្ការ បង់រំលស់ផ្ទះ រថយន្ត ម៉ូតូ និងទូរស័ព្ទជាដើម។ល។ ប៉ុន្តែលោក អ្នកដឹងទេថា តើអ្នកណា ឬប្រទេសណាដែលបង្កើតធនាគារមុនគេបង្អស់ក្នុងពិភពលោក?។ ផ្អែកតាមគេហទំព័រ Wikipedia ដ៏ល្បីល្បាញបង្ហាញថា ប្រវត្តិនៃធនាគារបានចាប់ផ្តើមកកើតដំបូងបង្អស់ គឺចេញពីពួកនាយទុន ឬឈ្មួញដោយគ្មានស្ថាប័នធនាគារដូចបច្ចុប្បន្ន ដែលមានអគារធំៗបែបនេះឡើយ។ នៅសម័យបុរាណឈ្មួញនៅទូទាំងពិភពលោកបានចងការប្រាក់ឱ្យកសិករ និងពាណិជ្ជករ ដែលដឹកទំនិញលក់ឆ្លងកាត់ពីក្រុងមួយទៅក្រុងមួយ។ ដំណើរកកើតនេះ គឺបានចាប់ផ្តើមប្រហែល២០០០ឆ្នាំ មុនគ្រិស្តសករាជនៅអាណាចក្រ Assyrian Empire ប្រទេសឥណ្ឌា និងអារ្យធម៌ Samaria។ ក្រោយមក នៅប្រទេសក្រិកសម័យបុរាណ និងចក្រភពរ៉ូម៉ាំង (Roman Empire) អ្នកចងការប្រាក់ ដែលរស់នៅតាមប្រាសាទ បានចាប់ផ្តើមផ្តល់ប្រាក់កម្ចី ឬចងការប្រាក់ ទទួលប្រាក់បញ្ញើ និងទទួលប្តូរប្រាក់។ ការសិក្សាបែបបុរាណវិទ្យាក្នុងប្រទេសចិន និងប្រទេសឥណ្ឌា សម័យបុរាណ ក៏បង្ហាញភ័ស្តុតាងបញ្ជាក់ពីការចងការប្រាក់ដែរ។ ប្រវត្តិសាស្ត្រជាច្រើនត្រូវបានកត់ត្រាថា សម័យកាលដ៏សំខាន់នៃការបង្កើតប្រព័ន្ធធនាគារជាប្រវត្តិសាស្ត្រ គឺនៅមជ្ឈិមសម័យ (សតវត្សរ៍ទី១៤-១៧) ជាពិសេសនៅតាមទីក្រុងមានទ្រព្យស្តុកស្តម្ភមួយចំនួនរបស់អ៊ីតាលី ដូចជា ក្រុង Florence ក្រុង Venice និងក្រុង Genoa ជាដើម។ យោងតាមការស្រាវជ្រាវបង្ហាញថា គ្រួសារដ៏មានឥទ្ធិពលចំនួនពីរ គឺត្រកូលអភិជន Bardi និងត្រកូលអភិជន Peruzzi បានត្រួតត្រាលើប្រព័ន្ធធនាគារ ក្នុងទីក្រុង Florence របស់អ៊ីតាលី ក្នុងសតវត្សរ៍ទី១៤ ដោយបានបង្កើតសាខានៅតំបន់ជាច្រើនទៀត នៃទ្វីបអឺរ៉ុប។ ធនាគារអ៊ីតាលី ដែលល្បីល្បាញបំផុតគឺធនាគារ Medici

8 https://thmeythmey.com/?page=detail&id=76035 (25-Feb-2024)
9 https://khemsarith.wordpress.com/ (25-Feb-2024)
10 https://web.facebook.com/100064228896213/posts/175682297801762/ (25-Feb-2024)
11 https://naraumelaw.files.wordpress.com/2013/09/sana-all-sorya-ume.pdf (25-Feb-2024)

Bank ដែលត្រូវបានបង្កើតឡើងដោយធនាគារិកជនជាតិអ៊ីតាលី ឈ្មោះ Giovanni Medici ក្នុងឆ្នាំ១៣៩៧។ ធនាគារដ៏ចំណាស់បំផុត ដែលនៅសល់ដល់សព្វថ្ងៃគឺធនាគារ Banca Monte dei Paschi di Siena ដែលមានទីស្នាក់ការកណ្តាល នៅទីក្រុង Siena ប្រទេសអ៊ីតាលី។ ធនាគារនេះ បានបើកដំណើរការជាបន្តចាប់តាំងពីឆ្នាំ១៤៧២។ រហូតដល់ចុងឆ្នាំ២០១៩ ធនាគារដ៏ចំណាស់បំផុតនេះ នៅតែដំណើរការនៅឡើយ គឺធនាគារ Banco di Napoli ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុង Naples ប្រទេសអ៊ីតាលី។

ធនាគារចុងក្រោយនេះ បានបើកដំណើរការតាំងពីឆ្នាំ១៤៦៣។ ការរីកចម្រើននៃវិស័យធនាគារ បានរីករាលដាលពីប្រទេសអ៊ីតាលី ភាគខាងជើងសាយភាយពាសពេញចក្រភពរ៉ូម៉ាំង ហើយនៅសតវត្សរ៍ទី១៥ និងទី១៦ បានសាយភាយទៅដល់អឺរ៉ុបខាងជើង។ ក្រោយមកទៀតវិស័យធនាគារ បានសាយភាយទៅដល់ក្រុង Amsterdam ប្រទេសហូឡង់ នៅសតវត្សរ៍ទី១៧ និងទៅដល់ទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស នៅសតវត្សរ៍ទី១៨។ អំឡុងសតវត្សរ៍ទី២០ ការរីកចម្រើនផ្នែកទូរគមនាគមន៍ និងប្រព័ន្ធកុំព្យូទ័របានធ្វើឱ្យប្រតិបត្តិការរបស់ធនាគារមានការផ្លាស់ប្តូរយ៉ាងខ្លាំង និងផ្តល់លទ្ធភាពឱ្យធនាគារនានាពង្រីកខ្លួនកាន់តែធំ និងកាន់តែច្រើនពាសពេញពិភពលោក រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ[12]។

### ២.២.៣ តួនាទីរបស់ធនាគារ

ធនាគារ គឺជាគ្រឹះស្ថានសេវាហិរញ្ញវត្ថុ ដែលផលិតនិងលក់មូលធនជាសាធារណៈប្រកបទៅដោយវិជ្ជាជីវៈ និងបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែក សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ធនាគារមានតួនាទីសំខាន់ៗជាច្រើនដូចជា៖

តួនាទីអន្តរការី៖ បង្វែរការសន្សំជាសាច់ប្រាក់ពីសាធារណជនឱ្យទៅជាឥណទានសម្រាប់សហគ្រាសពាណិជ្ជកម្មនិងសហគ្រាសផ្សេងទៀត ដើម្បីវិនិយោគនៅក្នុងការសាងសង់ សម្ភារបរិក្ខារ ឧបករណ៍ប្រើប្រាស់ និងសន្និធិ។ល។

តួនាទីទូទាត់៖គឺជាការអនុវត្តនូវការទូទាត់ផ្សេងៗសម្រាប់ទំនិញនិងសេវាកម្មក្នុងនាមជាអតិថិជរបស់ពួកគេដូចជា ការចេញនិងការទូទាត់ជម្រះមូលប្បទានបត្រផ្ទេរសាច់ប្រាក់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច និងការដកប្រាក់តាមប្រព័ន្ធម៉ាស៊ីនទំនើបអេធីអឹម( ATM )។

តួនាទីជាអ្នកធានា៖ ឈរពីខាងក្រោយអតិថិជនរបស់គេ ដើម្បីធ្វើការទូទាត់ ឬសងនូវបំណុលរបស់អតិថិជន នៅពេលដែលអតិថិជនទាំងនោះមិនអាចសងឱ្យទៅម្ចាស់បំណុលរបស់គេក្នុងកាលៈទេសៈចៃដន្យ ដោយធនាគារគ្រាន់តែចេញនូវលិខិតឥណទាន ដើម្បីបង្ហាញនូវទឹកប្រាក់នៅក្នុងគណនីអតិថិជនរបស់គេ។

តួនាទីគ្រប់គ្រងហានិភ័យ៖ ជួយទៅដល់អតិថិជនក្នុងការរៀបចំនូវការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់ការកើតមានហានិភ័យនៃការបាត់បង់ទ្រព្យសម្បត្តិ និងជីវិតមនុស្ស។

តួនាទីជាទីប្រឹក្សាលើការសន្សំ៖ ជួយដល់អតិថិជនលើការផ្តល់ការប្រឹក្សាយោបល់ សម្រាប់គោលដៅរយៈពេលវែងក្នុងការធ្វើឱ្យមានជីវិតល្អប្រសើរដូចជាគម្រោងសាងសង់ ឬគម្រោងអាជីវកម្មផ្សេងៗ ដើម្បីជៀសវាងទុកប្រាក់សន្សំមិនចរាចរនៅលើទីផ្សារ។

---

[12] https://propertyarea.asia/archives/79061 (25-Feb-2024)

តួនាទីជាអ្នកថែរក្សាវត្ថុមានតម្លៃ៖ ទុកដាក់វត្ថុមានតម្លៃរបស់អតិថិជននិងវាយតម្លៃប្រកបដោយភាពសុក្រិតភាពនូវតម្លៃរបស់ទ្រព្យសកម្មឬទ្រព្យសម្បត្តិ ដែលធ្វើប្រតិបត្តិការនៅលើទីផ្សារ។

តួនាទីជាភ្នាក់ងារ៖ ក្នុងនាមជាអ្នកតំណាងឱ្យអតិថិជនដើម្បីចាត់ចែង និងការពារនូវទ្រព្យសកម្មរបស់ពួកគេ ឬចេញនិងលស់ ឬទទួលទូទាត់លក់ចេញ និងទិញចូលនូវប័ណ្ណភាគហ៊ុននានា។ ជាធម្មតាសកម្មភាពទាំងនេះ ត្រូវបានផ្តល់ឱ្យដោយនាយកដ្ឋានសច្ចភាពរបស់ធនាគារ។

តួនាទីអ្នកអនុវត្តគោលនយោបាយ៖ ធ្វើប្រតិបត្តិការស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលបំណងឱ្យមានកំណើនសេដ្ឋកិច្ច និងឈានទៅដល់គោលដៅដែលសង្គមចង់បាន[13]។

**២.២.៤ មុខងាររបស់ធនាគារ**

សាជីវកម្ម ឧស្សាហកម្មធំៗ អតិថិជនម្នាក់ៗ អាជីវកម្មធុនតូចទាំងអស់ គឺអាស្រ័យលើធនាគារពាណិជ្ជ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុទាំងអស់។ បញ្ហាគន្លឹះសួរថា អ្វីជាចំណុចសំខាន់របស់ធនាគារ? អ្វីជាមុខងារដែលជាមូលដ្ឋានរបស់ធនាគារ?

ដូចនេះមានមុខងារបីយ៉ាងដែលគេចាត់ទុកថា ជាផ្នែកដ៏សំខាន់របស់ធនាគារនោះគឺ៖

- មុខងារទទួលប្រាក់បញ្ញើ (Deposit function)
- មុខងារធ្វើការទូទាត់ (Payment function)
- មុខងារផ្តល់ឥណទាន (Credit function) [14]។

**ក. មុខងារទទួលប្រាក់បញ្ញើ (Deposit Function)**

ជាការពិតតើគេធ្វើអ្វីខ្លះ?ហើយអ្នកណាជាអ្នកធ្វើ?ហើយគេធ្វើដើម្បីអ្វី?តើគេធ្វើការផ្ញើរបៀបម៉េច? ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីបង្កើតនិងស្រូបយកនូវការហូរចូលនូវប្រាក់បញ្ញើ និងសម្រាប់បង្កលក្ខណៈឱ្យកាន់តែមានភាពងាយស្រួលចំពោះអតិថិជនថែមទៀត បច្ចុប្បន្ននេះ ធនាគារបានបង្កើតលើនីតិវិធីបន្ថែមជាច្រើនទៀត ដែលក្នុងវិធីនោះ អាចឱ្យគេធ្វើប្រាក់បាន។

- សេវាមានលក្ខណៈងាយស្រួល (Convenience Service) ធនាគារជាច្រើនបានបង្កលក្ខណៈងាយស្រួលដែលគេបានហៅថាជាកន្លែង ឬជាប្រអប់ទទួលបញ្ញើដ៏មានសុវត្ថិភាពសម្រាប់បង្កលក្ខណៈងាយស្រួលដល់អតិថិជន។ ធនាគារ ក៏បានលើកទឹកចិត្តឱ្យមានការប្រើប្រាស់ នូវការផ្ញើតាមរយៈសំបុត្រដែលហាក់ដូចជាវិធីផ្សេងទៀត ដើម្បីបង្កើននូវការដោះស្រាយនូវការផ្ញើនេះ ហើយក៏បានកាត់បន្ថយនូវបញ្ហាចរាចរនៅក្នុងធនាគារ និងធ្វើឱ្យធនាគារកាន់តែមានការងាយស្រួលច្រើនឡើងសម្រាប់អតិថិជន។

- ប្រព័ន្ធផ្ទេរទូទាត់មូលនិធិតាមអេឡិចត្រូនិច (Electronic funds Transfer System) ការអភិវឌ្ឍន៍ប្រព័ន្ធផ្ទេរទូទាត់មូលនិធិតាមអេឡិចត្រូនិច បានបើកទូលាយក្នុងការឱ្យមានវិធីបន្ថែមទៀត ដែលនៅក្នុងវិធីនោះ អាចផ្ទេរមូលនិធិដល់គណនីនានា ដោយមិនចាំបាច់តម្រូវឱ្យអតិថិជនមកធនាគារ ឬក៏ចំណាយពេលច្រើនពេកក្នុងការមកធនាគារនោះទេ។

[13] https://khemsarith.wordpress.com/2016/the-roles-of-banks/ (25-Feb-2024)

[14] វិទ្យាស្ថានវ៉ាន់ដា សៀវភៅ រូបិយវត្ថុ និងធនាគារ ភាគ១ បោះពុម្ពលើកទី៥ ឆ្នាំ២០១៩ មានចំនួន៥៨ ទំព័រ ចាប់ពីទំព័រទី ៥១ ដល់ទំព័រទី ៥៥

- ប្រាក់ផ្ទេរទូទាត់រវាងធនាគារ (Transfer Between Banks) ការផ្ទេរតាមរយៈខ្សែភ្លើងបានបង្ហាញនូវវិធីផ្សេងទៀតដែល នៅក្នុងវិធីនោះគេធ្វើឱ្យមានបញ្ញើកើតឡើងចំពោះគណនីមួយ ដោយមិនបាច់ទាក់ទងទៅនឹងអ្នកទទួលប្រាក់នៅក្នុងធនាគារនោះទេ។

- ការផ្ទេរទូទាត់នៅក្នុងធនាគារតែមួយ (Transfer Within a Bank) វិធីទូទាត់មួយដែលងាយទូទាត់បំផុតដែលប្រាក់កម្ចីនៅតែបន្តទៀតនោះ គឺប្រកាសឱ្យឥណទានចំពោះគណនីរបស់អ្នកខ្ចី។ ការបន្តនៃការលក់ធនប័ណ្ណ និងការប្រមូលនូវផ្នែកណាដែលមិនមែនជាសាច់ប្រាក់ ដូចជាលទ្ធផលមួយនៅក្នុងទម្រង់ជាសកម្មភាពបញ្ញើដែរ។

**ការត្រួតពិនិត្យប្រាក់បញ្ញើ (Examine Deposits)**

មុនពេលទទួលប្រាក់បញ្ញើពីអតិថិជន ជាការសំខាន់ណាស់ដែលត្រូវតែធ្វើការត្រួតពិនិត្យ នូវប្រាក់បញ្ញើនោះ ដូច្នេះធនាគារត្រូវតែដឹងនូវអ្វីដែលខ្លួនគួរទទួលយក។

- រូបិយបណ្ណក្លែងក្លាយ (Counterfeit currency) ការដោះស្រាយបញ្ហារូបិយប័ណ្ណក្លែងក្លាយជាបញ្ហាសំខាន់ណាស់ សម្រាប់អ្នកទទួលប្រាក់ទោះបីកាលៈទេសៈណា ក៏ដោយលុយក្លែងក្លាយនឹងត្រូវបង្វិលឱ្យអ្នកផ្ញើវិញ។ ជាការច្បាស់ណាស់ អ្នកផ្ញើត្រូវតែបាត់នូវចំនួនលុយបែបហ្នឹង ដែលគេបានប្រទះឃើញនៅក្នុងបញ្ញើជារូបិយប័ណ្ណរបស់ខ្លួននោះ។

- បង្អិលេខ (Endorsement) មូលប្បទានបត្រដែលគេបានបង្ហាញសម្រាប់ធ្វើការដូរប្រាក់ និងសម្រាប់ធ្វើការផ្ញើ នឹងត្រូវបានគេត្រួតពិនិត្យនូវការចារលើខ្នងសំបុត្រនោះឱ្យបានត្រឹមត្រូវ។ ដោយទទួចឱ្យមានបង្អិលេខឱ្យបានត្រឹមត្រូវនោះ អ្នកទទួលប្រាក់មានការចាប់អារម្មណ៍បំផុតទាំងលើផ្នែកធនាគារ និងអតិថិជន។

- ការផ្ញើរបស់អាជីវកម្ម (Business Deposit) តាមក្បួនច្បាប់ជាទូទៅ រូបិយប័ណ្ណ និងមូលប្បទានបត្រត្រូវបានគេរាប់ហើយត្រួតពិនិត្យ ទោះបីជាអតិថិជន អាជីវកម្មភាគច្រើនធ្វើការផ្ញើនូវទឹកប្រាក់ច្រើនៗបែបណាក៏ដោយ។ ការអនុវត្តរបស់ធនាគារដែលមានលក្ខណៈស្តង់ដារ អនុញ្ញាតឱ្យទទួលប្រាក់បញ្ញើទាំងនេះ ដោយធ្វើការរាប់ និងផ្ទៀងផ្ទាត់មើលឱ្យបានច្បាស់ ដោយអ្នកទទួលប្រាក់នៅពេលគេផ្ញើ។ នៅក្នុងករណីនេះ ជានាគារនិងអ្នកផ្ញើឯកភាពថា ចំនួននៃប្រាក់បញ្ញើ គឺជាប្រធានបទមួយសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើកក្រោយដែលអាចពាក់ព័ន្ធនូវការត្រួតពិនិត្យទ្វេគុណថែមទៀត។

**ខ. មុខងារទូទាត់ (Payment Function)**

មូលប្បទានបត្រ គឺជាយានមួយមានសុវត្ថិភាព និងមានការងាយស្រួលបំផុតសម្រាប់ធ្វើការទូទាត់និងត្រូវបានគេទទួលយកដោយមានភាពជឿជាក់ និងត្រឹមត្រូវ។ ឧទាហរណ៍ លុយគឺងាយស្រួលនឹងបាត់ និងគេលួចណាស់ បើសិនជាគេធ្វើការទូទាត់ជាសាច់ប្រាក់នោះ ចំណូលខ្លះដែលផ្តល់ឱ្យនោះ ក៏អាចបាត់បង់។ ដោយការកែលម្អនូវយន្តកម្មទូទាត់ចេះតែមានបន្តទៀតនោះ ធនាគារមានការចូលរួមយ៉ាងច្រើនដល់សេដ្ឋកិច្ចនិងមានការស្រាវជ្រាវសម្រាប់ស្វែងរកវិធីដ៏ប្រសើរបំផុត ដើម្បីបម្រើនូវអត្ថប្រយោជន៍អតិថិជន និងធនាគារហើយបញ្ហានេះ នាំទៅដល់ការអភិវឌ្ឍនូវប្រព័ន្ធផ្ទេរទូទាត់មូលនិធិតាមប្រព័ន្ធអេឡិចត្រូនិចមួយចំនួន។ តាមចំនួនចេះតែកើនឡើងនេះ អតិថិជនក៏បានកំពុងតែប្រើប្រាស់ប្រព័ន្ធ ATMs ដើម្បីទទួលសាច់ប្រាក់ដោយមិនចាំបាច់ចេញមូលប្បទានបត្រទេដែលជំនួសដោយកាត (Card)។

**គ.មុខងារឥណទាន (Credit function)**

- **ប្រភេទជាមូលដ្ឋាននៃការឱ្យខ្ចីរបស់ធនាគារ (The basic of bank loan)**

ចំពោះគោលបំណងនៃការធ្វើរបាយការណ៍ជូនទៅភ្នាក់ងាររដ្ឋាភិបាល និងសម្រាប់គោលបំណងនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួននៅក្នុងការធ្វើផែនការ និងការត្រួតពិនិត្យនោះ ធនាគារពាណិជ្ជបានចែកក្រុមកម្ចីរបស់ខ្លួនជាបួនផ្នែកគឺៈ

- កម្ចីទៅឱ្យអ្នកប្រើប្រាស់ (Consumer loan) ធនាគារពាណិជ្ជនានាបានធ្វើការផ្លាស់ប្តូរនូវការយកចិត្តទុកដាក់របស់ខ្លួនភាគច្រើនទៅផ្នែកលក់រាយ ហើយតម្រូវការ និងការបំពេញចិត្តដល់អ្នកប្រើប្រាស់ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលធនាគារមិនអាចមើលរំលងបាន។

- កម្ចីលើអចលនទ្រព្យ (Real estate loan) នៅអំឡុងពេលថ្មីៗនេះ ធនាគារនានាមានទំនាក់ទំនងយ៉ាងខ្លាំង នៅក្នុងប្រភេទមួយចំនួននៃការធ្វើហិរញ្ញប្បទានទៅខាងផ្នែកអចលនទ្រព្យ។ គេក៏បានផ្តត់ផ្គង់នូវមូលនិធិដែលគេត្រូវការសម្រាប់សំណង់ការិយាល័យថ្មីៗហាងទំនិញ និងការអភិវឌ្ឍលំនៅដ្ឋានឯកជនផ្សេងៗទៀត។ការអភិវឌ្ឍរបស់ខ្លួនមានទម្រង់ពីរជាសំខាន់គឺកម្ចីលើផ្នែកសំណង់ និងកម្ចីលើផ្នែករបស់ដាក់បញ្ចាំ។

- កម្ចីលើផ្នែកអន្តរធនាគារ (Interbank loan) កម្ចីលើផ្នែកនេះ ដែលគេប្រើសម្រាប់ធ្វើការចាត់ថ្នាក់កម្ចីរបស់ធនាគារ សំដៅទៅលើការធ្វើឥណទានដោយផ្ទាល់ ដោយធនាគារមួយទៅឱ្យធនាគារមួយទៀត ជាញឹកញយសំដៅលើមូលដ្ឋាននៃភាពទំនាក់ទំនងនឹងគ្នា។

- កម្ចីទៅឱ្យផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្ម (Commercial and industrial loan) កម្ចីលើផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្ម គឺជាផ្នែកមួយដ៏ធំនៃការឱ្យខ្ចីរបស់ធនាគារ។ កម្ចីខ្លះគេធ្វើក្នុងរយៈពេលវែងជាងមួយឆ្នាំ ភាគច្រើនកម្ចីផ្នែកនេះមានរយៈពេលតិចជាងនេះហើយរយៈពេលកំណត់ជាទូទៅគឺមានត្រឹម៩០ថ្ងៃ។

- **ការវិភាគឥណទាន (Credit analysis)**

គោលបំណងជាមូលដ្ឋាន នៃការឱ្យខ្ចីទៅលើផ្នែកពាណិជ្ជកម្ម និងការប្រើប្រាស់គឺធ្វើឱ្យកម្ចីនោះទទួលបាននូវប្រាក់ចំណេញដោយមានហានិភ័យទាបបំផុត ហើយការគ្រប់គ្រងនឹងត្រូវកំណត់ឱ្យបានច្បាស់លាស់ដែលនៅក្នុងនោះមន្ត្រីទទួលបន្ទុកការឱ្យខ្ចីត្រូវតែមានជំនាញច្បាស់លាស់។

ការអភិវឌ្ឍអាជីវកម្ម គឺជាដំណើរការនៃសេវាទីផ្សាររបស់ធនាគារ ចំពោះអតិថិជនមានស្រាប់ និងសំដៅទៅលើអតិថិជនសក្តានុពល។ ចំណុចចាប់ផ្តើម ជាធម្មតានៃការខិតខំប្រឹងអភិវឌ្ឍន៍អាជីវកម្ម គឺការស្រាវជ្រាវទីផ្សារ ហើយការគ្រប់គ្រងគួរនឹងបង្កើតនូវគោលដៅសំខាន់ៗមួយចំនួន សម្រាប់ដាក់ឱ្យមានកម្ចី និងការកំណត់ផ្នែកអាជីវកម្មដែលមានសក្តានុពល។

ការវិភាគឥណទានជាសំខាន់ គឺវិភាគទៅលើហានិភ័យនៃកំហុសឆ្គងដែលនៅក្នុងនោះ មន្ត្រីទទួលបន្ទុកឱ្យខ្ចីព្យាយាមវាយតម្លៃលទ្ធភាព និងឆន្ទៈរបស់អ្នកខ្ចីសម្រាប់ធ្វើការទូទាត់សង។ នីតិវិធីជាផ្លូវការនៃការវិភាគឥណទាន ជាប្រធានបទមួយសម្រាប់ធ្វើការវាយតម្លៃ នៃសំណើររបស់អ្នកខ្ចីនិងឱ្យមានការត្រួតពិនិត្យលម្អិតថែមទៀត នូវការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ។ ជាធម្មតាគេបានធ្វើការចាត់ថ្នាក់នូវកត្តាហានិភ័យសំខាន់ៗមួយចំនួន ដែលអាស្រ័យទៅលើ **Cs** ទាំងប្រាំនៃការផ្តល់ឥណទានទៅគេ។ **Cs** ទាំងប្រាំរួមមានៈ ចរិតលក្ខណៈ មូលធន សមត្ថភាព លក្ខខណ្ឌ និងទ្រព្យបញ្ចាំ។

- ចរិតលក្ខណៈ (Character) សំដៅទៅលើភាពស្មោះត្រង់របស់អ្នកខ្ចី។ បើសិនជា មានបញ្ហាធ្ងន់ធ្ងរនោះកម្ចីនានានឹងត្រូវបានគេធ្វើការបដិសេធ។

- មូលធន (Capital) សំដៅទៅលើការកំណត់ជំហរនូវទ្រព្យធនរបស់អ្នកខ្ចី។

- សមត្ថភាព (Capacity) ពាក់ព័ន្ធទាំងទៅលើជំហរច្បាប់របស់អ្នកខ្ចី និងជំនាញនៃការគ្រប់គ្រងនៅក្នុងការធ្វើប្រតិបត្តិការ។

- លក្ខខណ្ឌ (Condition) សំដៅទៅលើបរិយាកាសសេដ្ឋកិច្ច ឬកត្តាផលិតកម្ម និងការបែងចែកដែលមានឥទ្ធិពលទៅដំណើរការរបស់ក្រុមហ៊ុន។

- ទ្រព្យបញ្ចាំ (Collateral) គឺជាប្រភពទីពីរនៃការទូទាត់សងរបស់អ្នកខ្ចី នៅក្នុងករណីមានកំហុសឆ្គងណាមួយកើតឡើង ការត្រួតពិនិត្យឡើងវិញនូវឥណទាន (Credit review) ការខិតខំប្រឹងប្រែងនៃការឱ្យខ្ចីត្រូវបានគេប្រើប្រាស់ ក្រោយពេលមានការអនុម័តនូវការឱ្យខ្ចីរួចហើយ ត្រូវបានគេកំណត់គោលដៅដល់ការកាត់បន្ថយនូវហានិភ័យឥណទាន ព្រមទាំងដោះស្រាយនូវកម្ចីណាដែលមានបញ្ហា។ ដំណើរការនៃការត្រួតពិនិត្យអាចត្រូវបានគេបែងចែកទៅជាមុខងារះ

+ ត្រួតពិនិត្យនូវសកម្មភាពកម្ចីដែលមានស្រាប់ (Monitoring the performance of existing loan)
+ ដោះស្រាយនូវកម្ចីណាដែលមានបញ្ហា (Handing problem loan) ។

## ២.៣ នីតិវិធីនៃការគ្រប់គ្រងទ្រព្យសកម្ម

### ២.៣.១ និយមន័យ

**នីតិ** : គឺជាគ្រឿងណែនាំបែបផែន ជាទំនៀមទម្លាប់ប្រពៃណីឬជាបណ្តុំនៃវិធានគតិយុត្តិ ដែលត្រូវមានចំណងសិទ្ធនិងកាតព្វកិច្ចមានអានុភាពចាប់បង្ខំលក្ខណៈទូទៅមិនចំពោះ និងមានគោលដៅរៀបចំសណ្តាប់ធ្នាប់សាធារណៈ[15]។

**នីតិ** : គឺជាបណ្តុំវិធានគតិយុត្តិទាំងឡាយដែលមានគោលដៅ ធ្វើឱ្យសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម[16]។

**នីតិ** : ជាវិធានទាំងឡាយណាដែលគ្រប់គ្រងជីវភាពរស់នៅ ក្នុងសង្គមដោយមានការដាក់ទណ្ឌកម្មពីអំណាចសាធារណៈ[17]។

### ២.៣.២ ប្រវត្តិទាក់ទងនឹងនីតិ

នៅសម័យអង្គរប្រទេសកម្ពុជាពុំមានច្បាប់ទេអ្វីទាំងអស់គឺអាស្រ័យទៅលើការសម្រេចដ៏ខ្ពង់ខ្ពស់ លើអង្គព្រះមហាក្សត្រ។ អង្គព្រះមហាក្សត្រគឺជាចៅក្រម ឬអាជ្ញាកណ្តាលដ៏កំពូលក្នុងការដោះស្រាយវិវាទជូនប្រជារាស្ត្រក្នុងសវនាការ។ អ្នកចូលរួមផ្តល់យោបល់មានឥស្សរៈជនជាន់ខ្ពស់ ប្រចាំព្រះរាជវាំងឬនៅពេលខ្លះក៏ជាប្រជារាស្ត្រតូចតាច។ នៅសម័យនោះច្បាប់ឬបទបញ្ញត្តិផ្សេងៗគឺតែងត្រូវបានភ្នាក់ងាររាជការដើរស្រែកប្រកូកប្រកាសឬចារនៅលើផ្ទាំងសិលាហើយដាក់ផ្ទាំងផ្សព្វផ្សាយនៅតាមច្រកចេញចូលនៅតាមទីសាធារណៈ

[15] https://m.facebook.com/permalink.php?story_fbid=1563902050413910&id=1482208281916621 (25-Feb-2024)

[16] https://m.facebook.com/permalink.php?story_fbid=565184501339378&id=345437756647388 ( 25-Feb-2024)

[17] វិទ្យាស្ថាន វ៉ាន់ដា សៀវភៅ សេចក្តីផ្តើមនៃនីតិ បោះពុម្ពឆ្នាំ ២០១៩

ដូចជាប្រាសាទ ឬក្លោងទ្វារព្រះបរមរាជវាំងជាដើមហើយដើម្បី រក្សានូវបទបញ្ញត្តិទាំងនោះក៏មានការចារិកនៅលើស្បែកសត្វនិងលាបនឹងខ្ទុកម្សៅក្សណ៍។ល។

ក្រោយសម័យអង្គរ ច្បាប់ទម្លាប់ត្រូវបានបង្កើតឡើងបន្តិចម្តងៗជាបន្តបន្ទាប់។ សិលាចារិកបានបង្ហាញថា ប្រជារាស្ត្រត្រូវតែគោរពវិធានផ្សេងៗដែលបានកំណត់ ការមិនគោរពនិងបណ្តាលឱ្យមានការដាក់ទណ្ឌកម្មដែលធានាដោយអាជ្ញាធរសាធារណៈ។

នៅក្នុងគ្រិស្តសករាជ្យ៦២០ ក្នុងរាជ្ជកាលព្រះបាទជ័យជេដ្ឋាច្បាប់ខ្មែរ ក៏ត្រូវបានរៀបរៀងឡើងបន្ទាប់មកមានការកែលម្អ និងពិនិត្យឡើងវិញក្នុងរាជ្ជការព្រះបាទអង្គឌួង(១៨៤៧-១៨៦០)។ គេសង្កេតឃើញថា ច្បាប់ទាំងនោះត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីព្រះពុទ្ធសាសនា។ ក្រោយមក ប្រព័ន្ធច្បាប់ខ្មែរត្រូវបានផ្លាស់ប្តូរនៅក្រោយ ដែលកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំង ពិសេសនៅក្រោយ ឆ្នាំ១៩១០[18]។

**២.៣.៣ ប្រភេទនៃនីតិ**

ប្រទេសកម្ពុជា បច្ចុប្បន្នជាប្រទេសកាន់ប្រព័ន្ធច្បាប់ស៊ីវិលតែដោយសារការវិវត្តន៍ខ្លួនកន្លងមកឆ្លងកាត់នូវដំណាក់កាលលំបាកៗ និងមនោគមវិជ្ជាខុសៗគ្នា ដូចសម័យមុនឆ្នាំ១៩៧៥ ក្រោយមក១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ និងក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ក៏ទទួលឥទ្ធិពលខ្លាំងពីប្រព័ន្ធច្បាប់ផ្សេងៗ។

ច្បាប់៖គឺជាវិធានដែលអនុម័តដោយអង្គការនីតិបញ្ញត្តិឬ ដោយប្រជាមតិ[19]។

នីតិត្រូវបានបែងចែកជាពីរគឺនីតិជាតិនិងនីតិអន្តរជាតិ។ នីតិជាតិបែងចែកជាពីរផងទៀតផងដែរគឺនីតិជាតិសាធារណៈ និងនីតិជាតិឯកជន។ ចំពោះនីតិអន្តរជាតិវិញ ត្រូវបានធ្វើការបែងចែកចេញជាពីរគឺ នីតិអន្តរជាតិសាធារណៈ និងនីតិអន្តរជាតិឯកជន។

នីតិជាតិសាធារណៈមានជារួមដូចជា៖នីតិរដ្ឋធម្មនុញ្ញ នីតិរដ្ឋបាល នីតិព្រហ្មទណ្ឌ នីតិពន្ធដារ។ ចំណែកឯនីតិឯកជនវិញមានដូចជា ៖ នីតិរដ្ឋប្បវេណី នីតិការងារ នីតិនីរភ័យសង្គម នីតិពាណិជ្ជកម្ម ។

នីតិសាធារណៈគឺជាវិធានទាំងឡាយដែលមានក្នុងរដ្ឋមួយសំដៅលើការរៀបចំ និងការប្រព្រឹត្តរបស់អង្គការស្ថាប័នសាធារណៈព្រមទាំងសម្រាប់គ្រប់គ្រងទំនាក់ទំនងរវាងអង្គការរដ្ឋ និងបុគ្គលិករដ្ឋជាមួយនិងពលរដ្ឋរបស់ខ្លួន។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ គឺជាច្បាប់រៀបចំអង្គការដែលមានចែងពីការអនុវត្តអំណាច មុខងារ តួនាទី និងភារកិច្ច របស់ក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការអភិវឌ្ឍន៍មូលដ្ឋានឱ្យមានការរីកចម្រើនប្រកបដោយចីរភាព និងមានគណនេយ្យភាព ចំពោះការបំពេញតួនាទីរបស់ខ្លួនជាមួយច្បាប់នេះ ក៏មានចែងផងដែរពីការចូលរួមរបស់ប្រជាពលរដ្ឋទៅក្នុ ងដំណើរការកសាងផែនការ និងការងារផ្សេងទៀតក្នុងឃុំសង្កាត់ផងដែរ។ នីតិសាធារណៈរួមមាន នីតិរដ្ឋធម្មនុញ្ញ នីតិរដ្ឋបាល នីតិហិរញ្ញវត្ថុ នីតិព្រហ្មទណ្ឌ។

នីតិរដ្ឋធម្មនុញ្ញ គឺជាទូទៅគេបានឱ្យនិយមន័យរដ្ឋធម្មនុញ្ញថាជាច្បាប់គ្រឹះ និងជាច្បាប់កំពូលនៃរដ្ឋដែលជាទូទៅតែងកំណត់នៅរចនាសម្ព័ន្ធមុខងារជាមូលដ្ឋាននៃរដ្ឋ និងស្ថាប័នរដ្ឋសំខាន់ៗព្រមទាំងកំណត់នូវសិទ្ធិនិងកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ។

[18] ដកស្រង់ចេញពីសេចក្តីផ្តើមនៃនីតិខ្មែររៀបរៀងដោយ៖ កៅ មុយថង, មុនី វីរៈ, វ៉ាន់ ច័ន្ទតារា ទំព័រទី ១៥

[19] វិទ្យាស្ថាន វ៉ាន់ដា សៀវភៅ សេចក្តីផ្តើមនៃនីតិ ភាគ ១ បោះពុម្ពលើកទី ៩ ឆ្នាំ ២០២២ មាន១០១ទំព័រ ក្នុងទំព័រទី៤

នីតិរដ្ឋបាល គឺជាវិធានទាំងឡាយសម្រាប់រៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធររដ្ឋនិងជាវិធានកំណត់នូវទំនាក់ទំនងរវាងអាជ្ញាធររដ្ឋនិងប្រជាពលរដ្ឋរបស់ខ្លួន។

នីតិព្រហ្មទណ្ឌ គឺជាវិធានទាំងឡាយសំដៅលើ ការផ្តន្ទាទោសដល់ជនដែលប្រព្រឹត្ត ឬមានចេតនាប្រព្រឹត្តអំពើទុច្ចរិតសំដៅធ្វើឱ្យសង្គមគ្មានសុវត្ថិភាពនិងគ្មានរបៀបរៀបរយនៅក្នុងសង្គម។

នីតិហិរញ្ញវត្ថុ គឺជាវិធានទាំងឡាយដែលសំដៅលើការធានា ការគ្រប់គ្រង និងរៀបចំប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនិងនីតិវិធីរបស់វា។

នីតិឯកជន គឺជាវិធានទាំងឡាយដែលសំដៅធានាការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គលរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន។ នៅក្នុងនីតិជាតិឯកជនគេរាប់បញ្ចូលនីតិចំនួនបួនធំៗគឺ៖ នីតិរដ្ឋប្បវេណី នីតិការងារ នីតិនីរភ័យសង្គម នីតិពាណិជ្ជកម្ម។

នីតិរដ្ឋប្បវេណី គឺជាវិធាននានា សម្រាប់អនុវត្តរបស់ប្រជាពលរដ្ឋក្នុងគ្រប់ករណីទាំងអស់លើកលែងតែមានបទបញ្ញត្តិពិសេសផ្សេងទៀត។

នីតិការងារ គឺជានីតិពិសេសជាមែកធាងដែល កើតចេញពីនីតិរដ្ឋប្បវេណីដើម្បី គ្រប់គ្រងទំនាក់ទំនងរវាងម្ចាស់សហគ្រាសនិងកម្មករ។

នីតិនីរភ័យសង្គម ជាវិធានទាំងឡាយណាដែលទាក់ទិនទៅនឹង ការធានារ៉ាប់រងដល់អ្នកធ្វើការងារជាម្ចាស់និងកម្មករ នៅពេលមានជំងឺ ការសម្រាលកូន ការចិញ្ចឹមកូន នៅពេលមានគ្រោះថ្នាក់ការងារ នៅពេលបាត់បង់ការងារជាដើម។

នីតិពាណិជ្ជកម្ម នៅក្នុងនីតិឯកជនយើងអាចកត់សម្គាល់ឃើញ មាននីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌ នីតិកិច្ចការជំនួញ។ នីតិកិច្ចការជំនួញនេះមាន៖នីតិពាណិជ្ជកម្ម ហើយដែលនៅក្នុងនីតិពាណិជ្ជកម្មមាន នីតិក្រុមហ៊ុនជាដើម[20]។

# ២.៤ ផលប្រយោជន៍នៃការគ្រប់គ្រង

## ២.៤.១ និយមន័យ

**ការគ្រប់គ្រង(Management)** គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតអំពី 1-ការធ្វើផែនការ (Planning), 2-ការចាត់ចែង(Organizing), 3-ការដឹកនាំ(Leading), 4-ត្រួតពិនិត្យឡើងវិញ(Controlling), និង 5-ការធ្វើសេចក្តីសម្រេចចិត្ត(Decision making)[21]។

**ការគ្រប់គ្រង(Management)** គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[22]។

**ការគ្រប់គ្រង(Management)** គឺជាបណ្តុំនៃសកម្មភាពដែលបង្កើតឡើងដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងរបស់អង្គភាពតាមរយៈការប្រើធនធាននានា(Resources) ឱ្យប្រកបដោយប្រសិទ្ធភាព(Effectively) និងសក្តិសិទ្ធិភាព(Efficiently)[23]។

## ២.៤.២ ប្រវត្តិនាក់ទងការគ្រប់គ្រង

[20] ដកស្រង់ចេញពីសេចក្តីផ្តើមនៃនីតិខ្មែររៀបរៀងដោយ៖ កៅ មុយថង, មុនី វីរៈ, វ៉ាន់ ច័ន្ទតារា ទំព័រទី ១៧ (25-Feb-2024)

[21] សៀវភៅពុម្ពនៃវិទ្យាស្ថាន វ៉ាន់ដា (2017) PRICIPLE OF MANAGEMENT (25-Feb-2024)

[22] https://clubniset.wordpress.com/2011/05/31/ (25-Feb-2024)

[23] https://web.facebook.com/HeartBookCambodia/posts/5646929262067994/?locale=hi_IN (25-Feb-2024)

គេបានរកឃើញប្រវត្តិនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងប្រទេសអង់គ្លេស ដែលទីនោះពួកគេជាជាងកំបោរ ជាងឈើ ជាងសម្លាប់ស្បែកសត្វ និងពួកអ្នកធ្វើខាងការងារកសិកម្ម បានប្រមូលគ្នាជាក្រុមចាប់អាជីពក្នុងសង្គមតាំងពីសម័យនោះ។ ពួកគេបានប្រើប្រាស់ការរស់នៅជាក្រុមដោយឯកភាពបែបនេះគឺដើម្បីការងារមានភាពងាយស្រួលដល់ការងារប្រចាំថ្ងៃរបស់ពួកគេ។ ការរស់នៅបែបនេះបានរីកចម្រើនជាមួយការមកដល់នៃបដិវត្តន៍ឧស្សាហកម្មនៅចុងសតវត្សទី១៨ ដែលបានក្លាយជាមូលដ្ឋានសម្រាប់សង្គម[24]។

**២.៤.៣ គម្រិតនៃការគ្រប់គ្រង**

ទ្រឹស្តីនៃការគ្រប់គ្រងបានចែងថារាល់អង្គភាព ឬសហគ្រាសត្រូវការ ការគ្រប់គ្រងដើម្បីសម្រេចគោលដៅរបស់ខ្លួនជាមួយនឹង ការប្រើប្រាស់ធនធានទាំងឡាយឱ្យមានប្រសិទ្ធភាពបំផុត។ រីឯទ្រឹស្តីសេដ្ឋកិច្ចក៏បានអះអាងដែរថាធនធានតែងបានតម្លៃនៃកាលានុវត្តភាព (Opportunity Cost) របស់ខ្លួន។

ដូចនេះអ្នកទទួលខុសត្រូវរបស់អង្គភាពត្រូវចេះគ្រប់គ្រង និងប្រើប្រាស់នូវធនធានដែលមានឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលមកវិញច្រើនតាមរយៈ ការធ្វើផែនការ ការចាត់ចែង ការទទួលបាន ការចែកចាយការដឹកនាំនិងការត្រួតពិនិត្យលើការប្រើប្រាស់ធនធានទាំងនោះឱ្យជាប្រយោជន៍ដល់អង្គភាព។ ដូច្នេះហើយគេត្រូវការ ការគ្រប់គ្រងវាឱ្យបានល្អប្រសើរ។

ក្នុងបណ្តាធនធានខាងលើដែលអង្គភាពប្រើប្រាស់ មានតែធនធានមនុស្សប៉ុណ្ណោះ ដែលជាធនធានមានជីវិត។ សភាពជាមនុស្ស ជាសភាវៈដែលចេះគិតនិងពិចារណាមានអារម្មណ៍សញ្ចេតនាដូចនេះ ពួកគេនឹងអាចបំពេញការងារមានប្រសិទ្ធភាពខ្ពស់ កាលណាគេពេញចិត្តអង្គភាពផ្ទុយទៅវិញ គេអាចនឹងចាកចេញពីអង្គភាពនៅពេលដែលគេមិនពេញចិត្ត។ ម្យ៉ាងវិញទៀត ដោយសារទាំងនេះជាធនធានដែលមានលក្ខណៈពិសេស វាទាមទារការគ្រប់គ្រងឱ្យបានល្អ ដើម្បីទទួលបានវិភាគទានពីធនធាននេះត្រឡប់មកវិញ សម្រាប់ការរីកចម្រើនរបស់អង្គភាព។

អ្នកគ្រប់គ្រងត្រូវបានបែងចែកជាបីប្រភេទដូចតទៅៈ

១- អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ (Top Managers) គឺជាក្បាលម៉ាស៊ីនបញ្ជានិងទទួលខុសត្រូវទៅលើរាល់ប្រតិបត្តិការទាំងអស់ របស់អង្គភាពអ្នកគ្រប់គ្រងនេះ គឺជាអ្នកផ្តួចផ្តើមបង្កើតរូបមន្តយុទ្ធសាស្ត្រ ក្នុងដំណើរការប្រតិបត្តិការរបស់អង្គភាព គេក៏ត្រូវសម្តែងផងដែរនូវភាពជាអ្នកដឹកនាំចាត់តាំងចំពោះការពង្រីកនូវកម្មវិធីធ្វើការងារតាមដានត្រួតពិនិត្យការវាយតម្លៃ និងជំរុញសកម្មភាពការងារឱ្យបានសម្រេចតាមគោលដៅ ដែលបានដាក់ចេញ។ ជាទូទៅគេមានឈ្មោះថាៈប្រធាន អនុប្រធាន នាយក ឬនាយករង។

២- អ្នកគ្រប់គ្រងថ្នាក់កណ្តាល(Middle Managers)គឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់លើអ្នកគ្រប់គ្រងថ្នាក់ទាប គឺជាអ្នកគ្រប់គ្រងនៅតាមបណ្តាផ្នែកជំនាញនីមួយៗ។ ឧទាហរណ៍ ផ្នែកគណនេយ្យហិរញ្ញវត្ថុ។ សំខាន់ជាងនេះទៀត ជាអ្នកគ្រប់គ្រងកណ្តាលជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការ និងគោលនយោបាយតាមផ្នែក របស់អង្គភាព ដើម្បីប្រមូលផ្តុំជាគោលដៅរួមសំដៅទៅលើការសម្រេចផែនការជារួម។

៣-អ្នកគ្រប់គ្រងថ្នាក់ទាប (Lowest Managers) គឺជាអ្នកដឹកនាំផ្ទាល់នៅរាល់សកម្មភាពការងាររបស់និយោជិក វាជាជំហានដំបូងនៃការគ្រប់គ្រងរបស់គេ គឺដឹកនាំសកម្មភាពការងាររបស់និយោជិកប្រចាំថ្ងៃដើម្បី

[24] http://sabeaninfo.blogspot.com/2012/01/blog-post.html?m=1 (25-Feb-2024)

អនុវត្តន៍តាមផែនការដែលបានដាក់ចុះ ដូចនេះ អ្នកគ្រប់គ្រងថ្នាក់ទាបត្រូវតែពាក់ព័ន្ធទៅនឹង ការត្រួតពិនិត្យផ្ទាល់លើការកែតម្រូវ ឬដោះស្រាយរាល់បញ្ហា ដែលទាក់ទងទៅនឹងការងារនោះប្រការនេះ អ្នកគ្រប់គ្រងថ្នាក់ទាបត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដំណើរការការងាររបស់អង្គភាព។ ឧទាហរណ៍ ៖ ប្រធានក្រុម ប្រធានផ្នែក[25]។

[25] https://www.khsearch.com/qna/24822 (25-Feb-2024)

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣
# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក. អ

## ៣.១ ស្ថានភាពទូទៅរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

### ៣.១.១ ប្រវត្តិរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជាធនាគារពាណិជ្ជមួយដែលរីកចម្រើនលឿនបំផុតក្នុងចំណោមធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខនៅក្នុងប្រទេសកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងខែកញ្ញាឆ្នាំ២០១៣ ក្រោមដៃគូយុទ្ធសាស្ត្ររវាងកាណាឌីយ៉ាអ៊ីនវេសមិនហូលឌីង ប្រៃសណីយ៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា និងហ្វូឡឺតុនហ្វាយណាន់ស្យលខាប់ពីតាល់ ភីធីអ៊ី (Fullerton Financial Capital Pte.)។ ចាប់ពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន ធនាគារបានវិវឌ្ឍន៍ខ្លួនទៅជាធនាគារពាណិជ្ជដ៏ល្អបំផុតមួយសម្រាប់អតិថិជនទូទៅនៅប្រទេសកម្ពុជា ដោយបានទទួលយកការអនុវត្តជាសាកលល្អបំផុត និងស្ថិតនៅជួរមុខគេក្នុងការទទួលយកគំនិតផ្តួចផ្តើមថ្មីៗផ្នែកបច្ចេកវិទ្យា។ ធនាគារ វាស់ស្ទង់ភាពជោគជ័យរបស់ខ្លួន មិនត្រឹមតែតាមរយៈចំនួនប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែធនាគារក៏មើលទៅលើសមិទ្ធផលសំខាន់ៗនានា ក្នុងការបំពេញតម្រូវការកើនឡើងរបស់អតិថិជន ដែលជួយឱ្យធនាគារ ក្លាយជាធនាគារដែលមានការប្រកួតប្រជែងធំបំផុតមួយ នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេល៩ ឆ្នាំនៃប្រតិបត្តិការ ធនាគារបានបោះជំហានយ៉ាងលឿនក្លាយជាធនាគារបែបឌីជីថល ដែលអនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់ និងគ្រប់គ្រងហិរញ្ញវត្ថុបានយ៉ាងងាយស្រួល និងមានសុវត្ថិភាពខ្ពស់បំផុតតាមរយៈទូរស័ព្ទដៃ។

បច្ចុប្បន្ន អតិថិជនអាចស្នើសុំឥណទាន និងស្នើសុំបើកគណនីតាមអនឡាញ ទូទាត់វិក្កយបត្រ និងធ្វើប្រតិបត្តិការនានា ដោយមិនចាំបាច់ធ្វើដំណើរមកកាន់សាខារបស់ធនាគារឡើយ។ ធនាគារ ក៏បានដាក់ឱ្យប្រើប្រាស់មុខងារ QRស្កេន ទូទាត់វិក្កយបត្រ សេវាបង់ប្រាក់ពន្ធ-អាករ សេវាផ្ទេរ និងទទួលប្រាក់ឆ្លងប្រទេសសេវាផ្ទេរប្រាក់ឆ្លងធនាគារតាមរយៈប្រព័ន្ធបាគង ប្រព័ន្ធរីធែលផេ (Retail Pay) ប្រព័ន្ធទូទាត់រហ័ស (FAST) បញ្ចូលទឹកប្រាក់ទូរស័ព្ទ និងមុខងារជាច្រើនផ្សេងទៀត ដែលធ្វើឱ្យប្រតិបត្តិការហិរញ្ញវត្ថុមានភាពងាយស្រួល និងមានសុវត្ថិភាព។ ដើម្បីធានាបាននូវសុវត្ថិភាព និងទំនុកចិត្តកាន់តែខ្ពស់ពីអតិថិជនក្នុងការធ្វើប្រតិបត្តិការនានាតាមប្រព័ន្ធឌីជីថល ធនាគារមិនត្រឹមតែមានប្រព័ន្ធប្រតិបត្តិការជានាសុវត្ថិភាព ២៤/៧ ប៉ុណ្ណោះទេ ធនាគារថែមទាំងបានធ្វើបច្ចុប្បន្នភាព(អាប់គ្រេត) ប្រព័ន្ធធនាគារស្នូលផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ធនាគារក៏មានសេវាធនាគារ៣៦៥ ថ្ងៃដែលបម្រើសេវាធនាគារជូនអតិថិជនជារៀងរាល់ថ្ងៃទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកបុណ្យជាតិផងដែរ។ បច្ចុប្បន្ន ធនាគារសម្រេចបាននូវទ្រព្យសកម្មសរុបជាង ១.២ ពាន់លានដុល្លារអាមេរិក ជាមួយនឹងបណ្តាញប្រតិបត្តិការសាខាលាតសន្ធឹងពេញផ្ទៃប្រទេសចំនួន៦០សាខា ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនដាក់ប្រាក់ សរុបជាង ៣២៤ទីតាំង ចំនួនគណនីអតិថិជន សរុបជាង៣០០.០០០គណនី ចំនួន ប័ណ្ណអេធីអឹម និងប័ណ្ណឥណពន្ធ សរុបជាង១០០.០០០ប័ណ្ណ និងដៃគូអាជីវកម្ម សរុបជាង៣០០.០០០កន្លែងទូទាំងប្រទេស។ ធនាគារ ក៏បានសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ដូចជា វីង និងទ្រូម៉ាន់នី ដែលធ្វើឱ្យអតិថិជនអាចទូទាត់សងប្រាក់កម្ចីវិញបានកាន់តែងាយស្រួល។ ធនាគារ បានចាប់ដៃគូជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង

ទៀតដូចជា អេ អឹម ខេ និងអម្រឹត ដែលអនុញ្ញាតឱ្យអតិថិជននៃស្ថាប័ននេះ អាចដកប្រាក់ពីម៉ាស៊ីនអេធីអឹម គ្នាទៅវិញទៅមកដោយឥតគិតថ្លៃ ដោយប្រើប្រាស់ប្រព័ន្ធ CSS របស់ ធនាគារជាតិ នៃកម្ពុជា។

ធនាគារចូលរួមក្នុងគំនិតផ្តួចផ្តើមផ្សេងៗរបស់រដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ចឡើងវិញ តាមរយៈ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងសាជីវកម្មធានាឥណទានកម្ពុជា។ ទាំងនេះ គឺជាការគាំទ្រ គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍ និងពង្រឹងសហគ្រាសធុនតូច និងមធ្យម ដែលជា ផ្នែកនៃយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ចក្នុងបរិបទថ្មី ២០២១-២០២៣។ ធនាគារ ក៏សម្រេចបាននូវប្រសិទ្ធនាម និង ពានរង្វាន់ជាច្រើនពីស្ថាប័នជាតិ និងអន្តរជាតិផងដែរ។ នៅឆ្នាំ២០២២ ធនាគារ បានទទួលពានរង្វាន់ «SME Financier of The Year-Asia» លំដាប់ថ្នាក់ Silver និង «Best Financier for Women Entrepreneurs» លំដាប់ថ្នាក់ Silver ក្នុងកម្មវិធី Global SME Finance Forum Award 2022 ដែលរៀបចំឡើងដោយ International Finance Corporation (IFC) និង វេទិកាហិរញ្ញវត្ថុសហគ្រាសខ្នាតតូច និងមធ្យម (SME Finance Forum) សម្រាប់ការរួម ចំណែកគួរឱ្យកត់សម្គាល់ចំពោះសហគ្រាសធុនតូច និងមធ្យម និងជាពិសេសសម្រាប់សហគ្រិនស្ត្រីនៅកម្ពុជា។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក៏បានឈ្នះពានរង្វាន់ "Quality Achievements Award 2022" លំដាប់ថ្នាក់ "Platinum" ពីស្ថាប័ន European Society for Quality Research ('ESQR') ប្រទេសស្វីស សម្រាប់ការខិតខំ ប្រឹងប្រែង និងប្តេជ្ញាចិត្ត ក្នុងការផ្តោតលើការពង្រឹងគុណភាព របស់ខ្លួនក្នុងការផ្តល់សេវាកម្ម និង អភិវឌ្ឍន៍ ផលិតផលនានាផងដែរ។ ធនាគារប្តេជ្ញាក្នុងការកសាងគោលជំហរដ៏មុតមាំមួយប្រកបដោយក្រមសីលធម៌វិជ្ជា ជីវៈនិងបទដ្ឋានត្រឹមត្រូវក្នុងការថែរក្សា និងលើកកម្ពស់ប្រសិទ្ធភាពការងារដើម្បីនាំយកផលិតផលនិង សេវាកម្ម ល្អបំផុតជូនអតិថិជននៅប្រទេសកម្ពុជា។ ធនាគារកំពុងព្យាយាមសម្រេចឱ្យបាននូវ ចក្ខុវិស័យ "គ្រួសារមួយ គណនីមួយ"។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ធនាគារ មានបណ្តាញ ប្រតិបត្តិការ ចំនួន៥១សាខា គ្របដណ្តប់យ៉ាងទូលំទូលាយនៅទូទាំងប្រទេសផងដែរ។ ធនាគារ ផ្តល់ជូននូវ ផលិតផលជាច្រើនប្រភេទ ដើម្បីបំពេញតម្រូវការទីផ្សារដ៏ធំនៅកម្ពុជា។ ធនាគារប្តេជ្ញារចនា និងផ្តល់នូវផលិតផល ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ជូនអតិថិជន និងកំណត់ស្តង់ដារសេវាកម្មល្អបំផុតមួយនៅក្នុងប្រទេសកម្ពុជា។



### ៣.១.២ គោលនយោបាយរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

គោលនយោបាយគ្រប់គ្រងទ្រព្យសកម្ម ពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណេត និងបន្តការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមរយៈការវិនិយោគ បច្ចេកវិទ្យាជឿនលឿនពង្រឹងសមត្ថភាពធនធានមនុស្សព្រមទាំងពង្រឹងនិងកែលម្អដំណើរការអាជីវកម្ម។

### ៣.១.៣ បេសកកម្ម និង ទស្សនវិស័យរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

#### ក. បេសកកម្ម

បេសកកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ គឺចូលរួមអភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតតាមតម្រូវការទីផ្សារ ព្រមទាំងបម្រើសេវាល្អបំផុត ជូនអតិថិជន។

#### ខ. ទស្សនវិស័យ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺជាធនាគាពាណិជ្ជមួយ ដែលរីកចម្រើនលឿនបំផុតក្នុងចំណោមធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខនៅក្នុងប្រទេសកម្ពុជាក្នុងការផ្តល់សេវាហិរញ្ញវត្ថុល្អបំផុតជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសមាគមន៍។

#### គ.ចក្ខុវិស័យ

ចក្ខុវិស័យរបស់ធនាគារ គឺកែប្រែឱ្យទៅជាធនាគារដែលផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេជូនដល់អតិថិជនគ្រប់កម្រិតដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណងរីកចម្រើនរបស់ប្រជាជនកម្ពុជា ហើយបង្កើតតម្លៃជានិរន្តរ៍ដល់ភាគទុនិក បុគ្គលិក និងសង្គម។






### ៣.១.៤ និមិត្តសញ្ញា និងអត្តសញ្ញាណរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

និមិត្តសញ្ញារបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

- អត្ថន័យនៃពណ៌៖ ពណ៌ទឹកក្រូច គឺ Enthusiasm ដែលមានន័យថា រីករាយ
- អត្ថន័យនៃរូបរាងនិមិត្តសញ្ញាឡូកូ៖ ជា"សញ្ញាអនន្ត" ដែលមានន័យថា មិនអាចគណនា ឬរាប់បាន
- អត្តរួម៖"ផ្តល់ឱកាសឥតដែនកំណត់"សម្រាប់អតិថិជនទាំងខាងក្នុងនិង ខាងក្រៅរបស់ខ្លួន។

### ៣.១.៥ រចនាសម្ព័ន្ធរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ



## ៣.២ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារប្រៃសណីយ៍កម្ពុជា គឺជាធនាគារដែលមានប្រព័ន្ធគ្រប់គ្រងរឹងមាំ ដោយមានការជឿទុកចិត្តពីសាធារណៈជននិង ជាធនាគារឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ ដោយឡែកចំពោះទ្រព្យសកម្មរបស់ធនាគារវិញមានច្រើនប្រភេទដូចជា៖

- សាច់ប្រាក់ក្នុងដៃ
- ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា-សុទ្ធ
- ប្រាក់តម្កល់តាមច្បាប់
- ឥណទាននិងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ
- ទ្រព្យសកម្មផ្សេងៗ
- ទ្រព្យសកម្មអរូបី
- ទ្រព្យនិងបរិក្ខារ
- សិទ្ធប្រើប្រាស់ទ្រព្យសកម្ម
- តម្លៃកេរ្តិ៍ឈ្មោះ
- ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ

**ក. សាច់ប្រាក់ក្នុងដៃ**

គឺជាប្រាក់ដែលយើងបានមកពីដើមទុនខ្លះ ប្រាក់បញ្ញើរបស់អតិថិជនខ្លះ និងចំណូលផ្សេងៗទៀត ដោយដកមួយចំណែក ដើម្បីរក្សាទុកការពារក្នុងធនាគារនៅពេលអតិថិជនមកដកប្រាក់វិញ ឬសម្រាប់ប្រើប្រាស់ក្នុងអង្គភាព។

**ខ. ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា-សុទ្ធ**

គឺការទទួលប្រាក់បញ្ញើពីគ្រឹះស្ថានផ្សេងៗ ប្រាក់បញ្ញើមានកាលកំណត់គណនីសន្សំប្រាក់បញ្ញើតាមតម្រូវការ ការប្រាក់បង្គរតាមការទូទាត់។

**គ. ប្រាក់តម្កល់តាមច្បាប់**

គឺជាសម្ព័ន្ធរបស់ធនាគារ និងធនាគារតម្រូវឱ្យមានប្រាក់តម្កល់តាមច្បាប់ចំនួន 10% នៃដើមទុនរបស់ខ្លួន(បុត្រសម្ព័ន្ធ 5%)។

**ឃ. ឥណទាននិងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ**

គឺធនាគារប្រៃសណីយ៍កម្ពុជា អាចទទួលបានឥណទានដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនជាច្រើនដូចជា៖

- ឥណទានគ្មានទ្រព្យធានា
- ឥណទានរថយន្ត
- ឥណទានគេហដ្ឋាន
- ឥណទានកសិកម្ម
- ឥណទានមិនមែនកសិកម្ម
- ឥណទានខ្នាតតូច និងមធ្យម

- ការធានាអំពីធនាគារ
- រំដួល(ផ្ដល់អតិភាពចំពោះស្ត្រី)

**ង. ទ្រព្យសកម្មផ្សេងៗ**

សំដៅដល់ទ្រព្យសកម្មដទៃទៀតផ្សេងៗទៀតដែលមិនមានបញ្ជាក់លម្អិតក្នុងតារាងតុល្យការសម្រាប់ទ្រព្យសកម្មនៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

**ច. ទ្រព្យសកម្មអរូបី**

សំដៅដល់ទ្រព្យទាំងឡាយណា ដែលមិនមែនជាទ្រព្យរូបវន្ត ឬទ្រព្យហិរញ្ញវត្ថុ។ ទ្រព្យអរូបីអាចត្រូវបានកាន់កាប់ ឬគ្រប់គ្រងសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្ម។ បុគ្គលដែលមានលទ្ធភាពជាម្ចាស់ ឬអ្នកគ្រប់គ្រង ឬអ្នកប្រើប្រាស់ ឬទទួលសិទ្ធិប្រើប្រាស់នូវទ្រព្យអរូបីនោះ នឹងត្រូវទទួលបានមកវិញនូវ ផលប្រយោជន៍សេដ្ឋកិច្ច ក្នុងលក្ខខណ្ឌដែលប្រតិបត្តិការត្រូវបានធ្វើឡើងរវាងសហគ្រាសឯករាជ្យ ក្នុងកាលៈទេសៈដែលអាចប្រៀបធៀបបាន។ ទ្រព្យអរូបី ជាអាទិ៍មាន ប្រកាសនីយបត្រតក្កកម្ម ចំណេះដឹង ឬចំណេះធ្វើ ពាណិជ្ជសញ្ញា ពាណិជ្ជនាម សិទ្ធិចម្លង រចនាបថដែលបានចុះបញ្ជី សិទ្ធិប្រើប្រាស់អាជ្ញាប័ណ្ណ ស្នាដៃអក្សរសាស្ត្រ និងសិល្បៈ និងទ្រព្យប្រហាក់ប្រហែលផ្សេងទៀត ដែលមានតម្លៃជាកម្មសិទ្ធិបញ្ញា ឬអរូបីផ្សេងៗមានដូចជា ពាណិជ្ជសញ្ញា និងពាណិជ្ជនាម ជាដើម ដែលត្រូវបានកំណត់ថាជាទ្រព្យអរូបីទីផ្សារ។ ដោយឡែកប្រកាសនីយបត្រតក្កកម្មដែលជានិច្ចកាលកើតឡើងតាមរយៈការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែលមានហានិភ័យ និងចំណាយខ្ពស់ត្រូវបានកំណត់ថាជាទ្រព្យអរូបីពាណិជ្ជកម្ម។

**ឆ. ទ្រព្យ និងបរិក្ខារ**

គឺការកែលម្អអគារ បរិក្ខារការិយាល័យ សង្ហារិម គ្រឿងបំពាក់ និងបរិក្ខារ កុំព្យូទ័រនិងព័ត៌មានវិទ្យា យានយន្ត ទ្រព្យកំពុងបង្កើត ។

**ជ. សិទ្ធប្រើប្រាស់ទ្រព្យសកម្ម**

គឺជាគោលគំនិតផ្លូវច្បាប់ដែលផ្ដល់សិទ្ធិដល់បុគ្គល ឬអង្គភាពក្នុងការប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍នៃទ្រព្យសកម្មដែលជាកម្មសិទ្ធិរបស់ភាគីផ្សេង។ សិទ្ធិនេះ អនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចប្រើប្រាស់ទ្រព្យសកម្មក្នុងរយៈពេលជាក់លាក់មួយ ប៉ុន្តែ ពួកគេមិនមានសិទ្ធិជាម្ចាស់លើទ្រព្យសកម្មនេះឡើយ។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មអាចផ្ដល់នូវភាពបត់បែន និងមានលទ្ធភាពទទួលបាននូវធនធាន ដោយមិនមាននូវកម្មសិទ្ធិពេញលេញ ហើយវាគឺជាគំនិតសំខាន់មួយនៅក្នុងប្រតិបត្តិការផ្លូវច្បាប់ និងពាណិជ្ជកម្មផ្សេងៗ។

**ឈ. តម្លៃកេរ្តិ៍ឈ្មោះ**

ជាអតិរេកដោយផ្អែកលើតម្លៃតបស្នង នៃតម្លៃសមស្របនៃទ្រព្យសកម្ម។

**ញ. ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ**

សម្ព័ន្ធធនាគារមានពន្ធពន្យារ៣ គឺពន្ធពន្យារជាទ្រព្យសកម្ម ពន្ធពន្យារជាបំណុល ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ។

### ៣.២.១ ប្រភេទឥណទានរបស់ធនាគារប្រៃសណីយ៍កម្ពុជា ភ.អ

**ក. ឥណទានគ្មានទ្រព្យធានា**

ឥណទាននេះត្រូវបានបង្កើតឡើង ដើម្បីបំពេញនូវតម្រូវការទីផ្សារដែលខ្វះចន្លោះក្នុងប្រទេសកម្ពុជា ដោយផ្តោតសំខាន់លើអ្នកមានប្រាក់បៀវត្ស។ អតិថិជនគោលដៅគឺស្ថិតនៅទីក្រុង និងតំបន់ជនបទ ជាអ្នកមានប្រាក់បៀវត្ស។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់ឥណទានគ្មានទ្រព្យធានាត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់ ២៤ខែ
- មិនតម្រូវឱ្យមានទ្រព្យធានា
- ផ្តល់ទំហំឥណទានរហូតដល់ ៣០,០០០ ដុល្លារអាមេរិក
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- សេវាធនាគារចល័ត
- វិធីសងរំលស់មានភាពបត់បែន និងងាយស្រួល។

**ខ. ឥណទានរថយន្ត**

ឥណទាននេះធនាគារ នឹងបំពេញតម្រូវការជូនអតិថិជនទាំងអស់ផ្នែកហិរញ្ញវត្ថុសម្រាប់ប្រើប្រាស់ក្នុងការទិញរថយន្តឱ្យទទួលបាននូវរថយន្តយ៉ាងពិតប្រាកដតាមការប៉ងប្រាថ្នារបស់ខ្លួនភ្លាមៗ ដែលមានភាពសាមញ្ញជាមួយលក្ខខណ្ឌងាយស្រួល។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់ឥណទានរថយន្តត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់ ៩៦ខែ
- មិនតម្រូវឱ្យមានទ្រព្យធានា
- ផ្តល់ទំហំឥណទានរហូតដល់១០០,០០០ ដុល្លារអាមេរិក ឬ ៨០% នៃតម្លៃរថយន្ត
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- មានសេវាធនាគារចល័ត
- វិធីសងរំលស់មានភាពបត់បែន និងងាយស្រួល។

**គ. ឥណទានគេហដ្ឋាន**

ឥណទាននេះនឹងជួយលោកអ្នកអោយក្លាយជាម្ចាស់ គេហដ្ឋាន ខុនដូ ឬអាផាតមិនដ៏ប្រណិតបែបទាន់សម័យមួយភ្លាមៗ សម្រាប់រស់នៅជាមួយក្រុមគ្រួសារជាទីស្រលាញ់ ប្រកបដោយសេចក្តីសុខសុភមង្គលជាមួយនឹងឥណទានគេហដ្ឋាន ដែលតែងតែរង់ចាំបម្រើនូវសេវាហិរញ្ញវត្ថុ ជូនដល់ប្រជាជនកម្ពុជាទាំងអស់ដែលចង់បានគេហដ្ឋានផ្ទាល់ខ្លួននៅទូទាំងប្រទេស។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់ឥណទានគេហដ្ឋានត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់៣០០ខែ

- ផ្តល់ជូនរហូតដល់ ៧៥% នៃតម្លៃអចលនទ្រព្យ
- ប្តូររឹង និងប្តូរទន់សម្រាប់ទ្រព្យបញ្ចាំ
- ផ្តល់ទំហំឥណទានរហូតដល់ ២៥០,០០០ ដុល្លារអាមេរិក
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- សេវាធនាគារចល័ត
- វិធីសងរំលស់មានភាពបត់បែន និងងាយស្រួល។

**ឃ. ឥណទានកសិកម្ម**

ប្រសិនបើលោកអ្នកកំពុងតែមានកង្វះខាតផ្នែកហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្មរបស់លោកអ្នក វាមិនមែនជាក្តីកង្វល់សម្រាប់លោកអ្នកទៀតឡើយ ធនាគារ ប្រៃសណីយ៍កម្ពុជា នឹងចូលខ្លួនជួយជ្រោមជ្រែងរាល់បញ្ហាហិរញ្ញវត្ថុក្នុងវិស័យកសិកម្មរបស់លោកអ្នក ។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់ឥណទានកសិកម្មត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់ ៦០ខែ
- ប្តូររឹង និងប្តូរទន់សម្រាប់ទ្រព្យបញ្ចាំ
- ផ្តល់ទំហំឥណទានរហូតដល់ ៥០,០០០ ដុល្លារអាមេរិក
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- មានសេវាធនាគារចល័ត
- វិធីសងរំលស់មានភាពបត់បែន និងងាយស្រួល។

**ង. ឥណទានមិនមែនកសិកម្ម**

ឥណទានអាជីវកម្ម ឬមិនមែនកសិកម្មបង្កើតឡើងក្នុងគោលបំណងផ្តល់ជូន នូវហិរញ្ញវត្ថុសម្រាប់អតិថិជនដែលត្រូវការទុន សម្រាប់ធ្វើការបង្វិលក្នុងអាជីវកម្ម និងការពង្រីកអាជីវកម្មជាដើម។ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ នឹងស្ថិតនៅជាមួយលោកអ្នកនៅពេល ដែលលោកអ្នកមានតម្រូវការផ្នែកហិរញ្ញវត្ថុក្នុងអាជីវកម្ម។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់ឥណទានមិនមែនកសិកម្មត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់ ១២០ខែ
- ផ្តល់ជូនទំហំឥណទានរហូតដល់ ៧៥% នៃតម្លៃទ្រព្យធានា
- ប្តូររឹង និងប្តូរទន់សម្រាប់ទ្រព្យបញ្ចាំ
- ផ្តល់ទំហំឥណទានរហូតដល់ ២៥០,០០០ ដុល្លារអាមេរិក
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- មានសេវាធនាគារចល័ត
- វិធីសងរំលស់មានភាពបត់បែន និងងាយស្រួល។

**ច. ឥណទានសហគ្រាសខ្នាតតូច និងមធ្យម**

ធនាគារ ប្រៃសណីយ៍កម្ពុជាជឿជាក់លើសារៈសំខាន់នៃសហគ្រាសខ្នាតតូច និងមធ្យមក្នុងការចូលរួមឆ្ពោះទៅរកការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា។ ជាមួយនឹងកញ្ចប់ហិរញ្ញប្បទាន ពិសេសសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមយើងប្តេជ្ញាផ្តល់ជូនអ្នកនូវដំណោះស្រាយផ្នែកហិរញ្ញវត្ថុ ដើម្បីធានាថាលោកអ្នកនឹងទទួលបាននូវឱកាសក្នុងការបង្កើតអាជីវកម្មថ្មីៗ ការពង្រីកអាជីវកម្ម ដើមទុនសម្រាប់ប្រើប្រាស់ និងកែលម្អទីតាំងអាជីវកម្មរបស់អ្នក។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវបានកំណត់ដូចខាងក្រោម៖

- ផ្តល់អត្រាការប្រាក់ប្រកួតប្រជែង
- ផ្តល់រយៈពេលឥណទានរហូតដល់ ១២០ខែ
- ផ្តល់ជូនរហូតដល់ ៧៥% នៃតម្លៃអចលនទ្រព្យ
- អនុញ្ញាត ប្លង់រឹង និងប្លង់ទន់សម្រាប់ទ្រព្យបញ្ចាំ
- ផ្តល់ទំហំឥណទានរហូតដល់ ១.០០០.០០០ ដុល្លារអាមេរិក
- ផ្តល់ជូនប័ណ្ណវីសាដោយឥតគិតថ្លៃ
- មានសេវាកម្មធនាគារចល័ត
- វិធីសងរំលោះមានភាពបត់បែន និងងាយស្រួល។

## ៣.៣ នីតិវិធីនៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឱ្យមានប្រសិទ្ធភាព

ការគ្រប់គ្រង គឺមានសារៈសំខាន់ណាស់សម្រាប់គ្រប់គ្រងស្ថាប័នទាំងអស់ ដោយឡែកវិស័យធនាគារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច។ ដូច្នេះហើយ ការគ្រប់គ្រងធនាគារគឺជាកត្តាមួយ ដ៏សំខាន់ដែលអ្នកគ្រប់គ្រងត្រូវយកចិត្តទុកដាក់ខ្ពស់ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានដូចជា៖ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ធនធានរូបវន្ត...។ ដោយសារធនាគារដើរតួនាទីយ៉ាងសំខាន់ ក្នុងការកេណ្ឌប្រមូលនូវប្រភពធនធានពីសេដ្ឋកិច្ច ហើយផ្តល់ទៅឱ្យអ្នកត្រូវការ(អ្នកខ្ចី) ដែលអាចផ្តល់ឱកាសនៅក្នុងការវិនិយោគ ដែលសកម្មភាពហិរញ្ញវត្ថុវាមានសារៈសំខាន់ និងជានាដល់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឱ្យមានដំណើរការយ៉ាងរលូន និងមានប្រសិទ្ធភាព។

ធនាគារគឺជាអាជីវកម្មមួយដែលគេបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ។ ដើម្បីឱ្យទទួលបានប្រាក់ចំណេញ អ្នកគ្រប់គ្រងធនាគារ ឬម្ចាស់អាជីវកម្មត្រូវមានគោលដៅពីរសំខាន់គឺ៖ទី១ ព្យាយាមស្វែងរកអតិថិជនឱ្យយកប្រាក់មកផ្ញើ និងទី២ព្យាយាមឱ្យអតិថិជនមកខ្ចីប្រាក់។

ចំណែកឯទ្រព្យសកម្ម ក៏ជាប្រភពធនធានរបស់អង្គភាពអាជីវកម្ម។ ដូច្នេះ វាគឺមានសមាសធាតុដ៏មានតម្លៃអាចប្រើប្រាស់បាននៅក្នុងការអនុវត្តសកម្មភាពជាច្រើនដូចជា កត្តាផលិតកម្ម ការប្រើប្រាស់ការដោះដូរ។

ទ្រព្យសកម្ម មានតួនាទីសំខាន់ណាស់ ក្នុងការជម្រុញការបង្កើតសាច់ប្រាក់ ទ្រព្យសកម្មចែកចេញជាពីរប្រភេទធំៗគឺ៖

ទី១ ទ្រព្យសកម្មចរន្ត(Current Assets) សំដៅលើទ្រព្យទាំងឡាយណា ដែលអាចបំលែងជាសាច់ប្រាក់ក្នុងរយៈពេលតិចជាង ឬស្មើ១ឆ្នាំ។ ទ្រព្យសកម្មចរន្តរួមមាន សាច់ប្រាក់ក្នុងដៃ(Cash on hand) សាច់ប្រាក់

ក្នុងធនាគារ(Cash in Bank) ឥណទាននិងបុរេប្រទានអតិថិជន(Loan and Advance to Customer) និងទ្រព្យសកម្មចរន្តផ្សេងៗទៀត។

ទី២ អចលនទ្រព្យ(Fixed Assets) សំដៅលើទ្រព្យទាំងឡាយណា ដែលមានអាយុកាលវែងជាង១ឆ្នាំ ដោយវាចូលរួមគាំទ្រ និងជម្រុញដំណើរការអាជីវកម្ម។ អចលនទ្រព្យ ត្រូវបានចែកចេញជាពីរ គឺទ្រព្យរូបី (Tangible Assets) ដែលមានដូចជា សម្បត្តិ និងបរិក្ខារ(Properties and Equipment)ពន្ធពន្យារទ្រព្យ (Deferred tax Assets)។ ចំណែកឯទ្រព្យអរូបី(Intangible Assets) មានដូចជាផ្លាកសញ្ញាពាណិជ្ជកម្ម (Trade Mark) ប្រកាសនីបត្រតក្កកម្ម(Parent) ជាដើម។

**៣.៣.១ លក្ខណៈនៃការគ្រប់គ្រងទ្រព្យសកម្ម**

ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារមានលក្ខណៈ៤យ៉ាងដូចខាងក្រោម៖

**១.ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល(Liquidity management)**

គឺជាសកម្មភាពនៃការគ្រប់គ្រងសាច់ប្រាក់ក្នុងដៃ និងប្រាក់បម្រុង ដើម្បីធានាថា ធនាគារអាចមានសាច់ប្រាក់គ្រប់គ្រាន់ និងទាន់ពេលវេលាក្នុងការឆ្លើយតបទៅនឹងតម្រូវការពេលដែលអតិថិជនមកដកប្រាក់បញ្ញើក្នុងរយៈពេលខ្លី។

ទោះបីជាយ៉ាងណាក៏ដោយការគ្រប់គ្រងលើសាច់ប្រាក់ងាយស្រួលតែងតែមានហានិភ័យដោយចៀសមិនរួច ដែលគេហៅថាហានិភ័យសាច់ប្រាក់ងាយស្រួល (Liquidity Risk)។ហើយដើម្បីដោះស្រាយហានិភ័យនោះបាន ធនាគារអាចមានជម្រើសជាមូលដ្ឋានបួន(Shortfall)។

- ទីមួយ (Interbank Loan) គឺដើម្បីទទួលបាននូវទុនបម្រុងមកបំពេញលំហូរប្រាក់បញ្ញើតាមរយៈការខ្ចីប្រាក់ពីធនាគារផ្សេងៗទៀតនៅក្នុងទីផ្សារមូលនិធិសហព័ន្ធឬខ្ចីពីសារជីវកម្ម។
- ទីពីរ (Sale on Securities) គឺសម្រាប់ធនាគារក្នុងការលក់មួយចំនួននៃមូលបត្ររបស់ខ្លួនដើម្បីជួយលើលំហូរប្រាក់កញ្ញានេះ។
- ទីបី (Overnight loan/Borrow from Fed) ដែលធានាគារអាចប្រើប្រាស់សម្រាប់បំពេញប្រាក់បម្រុងកាតព្វកិច្ចបានគឺការទទួលនូវទុនបម្រុងខ្ចីពីធនាគារកណ្ដាល។
- ទីបួន (Reduce Loan) គឺធនាគារអាចទទួលបានចំនួនទឹកប្រាក់គ្រប់គ្រាន់ ក្នុងការបំពេញប្រាក់បម្រុងវិញបាននោះ គឺតាមរយៈដោយការកាត់បន្ថយ ឬផ្អាកចំពោះការផ្ដល់កម្ចីរបស់ខ្លួន ដើម្បីយកមកបំពេញកាតព្វកិច្ចប្រាក់បម្រុងនេះ។

**២.ការគ្រប់គ្រងលើទ្រព្យសកម្ម(Assets Management)** អ្នកគ្រប់គ្រងធនាគារត្រូវតែវិនិយោគនៅក្នុងទ្រព្យសកម្មទាំងឡាយណា ដែលផ្ដល់នូវប្រាក់ចំណេញខ្ពស់តាមរយៈអត្រាការប្រាក់ខ្ពស់ហើយមានហានិភ័យទាប។

**៣.ការគ្រប់គ្រងលើបំណុល (Liabilities Management)** ការព្រួយបារម្ភទីបី គឺទាក់ទងទៅនឹងលទ្ធភាពនៃការទូទាត់បំណុលសងទៅម្ចាស់បំណុលវិញឱ្យបានទាន់តាមកិច្ចសន្យា។

**៤.ការគ្រប់គ្រងដើមទុនគ្រប់គ្រាន់ (Capital Adequacy Management)** អ្នកគ្រប់គ្រងធនាគារត្រូវតែសម្រេចចិត្តថា តើបរិមាណនៃដើមទុនធនាគារគួររក្សានិងតម្កល់ប៉ុន្មាន ដើម្បីស្របតាមតម្រូវការនៃច្បាប់និងបង្កើតនូវភាពរឹងមាំសម្រាប់អតិថិជនរបស់ខ្លួន។

**៣.៣.២ ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសកម្ម**

ដើម្បីគ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាពធនាគារប្រៃសណីយ៍កម្ពុជាក.អ ត្រូវមាននីតិវិធី៤គឺ៖

- ព្យាយាមស្វែងរកអតិថិជនទាំងឡាយណា(អ្នកខ្ចី) ដែលនឹងមានចំណាយអត្រាការប្រាក់ខ្ពស់ ហើយមានឆន្ទៈខ្ពស់ក្នុងការសងប្រាក់
- ព្យាយាមទិញមូលបត្រទាំងឡាយណាដែលអាចផ្ដល់នូវប្រាក់ចំណូលខ្ពស់និងមានហានិភ័យទាប
- ព្យាយាមដើម្បីកាត់បន្ថយហានិភ័យ តាមរយៈការវិនិយោគតាមវិស័យផ្សេងៗគ្នា
- រក្សាសាច់ប្រាក់បម្រុង ដោយធ្វើយ៉ាងណាឱ្យសមនឹងតម្រូវការជាក់ស្ដែង។

## ៣.៤ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ មានផលប្រយោជន៍ណាស់គឺធ្វើឱ្យធនាគារនេះកើនទុនជារៀងរាល់ឆ្នាំ។

ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារប្រៃសណីយ៍កម្ពុជាក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅដោយអនុវត្តតាមទស្សនៈគ្រឹះសំខាន់បី "មនុស្ស ផែនដី និងប្រាក់ចំណេញ" ហើយធ្វើការកំណត់ជានិច្ចនូវសូចនាករសម្រាប់វាស់វែង និងរាយការណ៍អំពីសកម្មភាពនិងផលប៉ះពាល់ទៅលើសង្គម និងបរិស្ថានព្រមទាំងដើម្បីអនុវត្តនូវរចនាសម្ព័ន្ធរបាយការណ៍ ដោយផ្អែកជាចម្បងទៅលើការណែនាំក្នុងគំនិតផ្ដួចផ្ដើមនៃរបាយការណ៍ពិភពលោក (GRI)។

ដូចនេះ ហើយបានជាការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជាផ្ដល់សារៈសំខាន់ដល់ស្ថាប័ន និងសង្គមដូចជា៖

**ចំពោះស្ថាប័ន៖**

- ទ្រព្យសកម្មមានការកើនឡើងជាលំដាប់ដែលជាចំណូលដ៏ចម្បង ហើយក៏ជាផ្នែកមួយដ៏សំខាន់របស់អង្គភាពអាជីវកម្ម
- ការវិនិយោគជាមួយដៃគូអាជីវកម្មក្នុង និងក្រៅស្រុកក៏មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំដែលជាហេតុធ្វើឱ្យធានាគារអាចពង្រីកសាខាបានបន្ថែមច្រើនទៀត
- មានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម ធនាគារស្វ័យប្រវត្តិដើម្បីបម្រើអតិថិជននិងសាធារណជនឱ្យបាន២៤ម៉ោងយ៉ាងឆាប់រហ័សទាន់ពេលវេលាទៅតាមតម្រូវការដែលចង់បាន
- បន្តលើកកម្ពស់ការអភិវឌ្ឍន៍ Fin Tech ដើម្បីផ្ដល់ភាពកាន់តែងាយស្រួលប្រើប្រាស់ដល់អតិថិជនក្នុងការផ្លាស់ប្ដូរទៅតាមការប្រើប្រាស់សេវាធនាគារតាមបែបឌីជីថល (ស្វ័យសេវា)
- ពង្រឹងសមត្ថភាពក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីអាចប្រកួតប្រជែងនៅលើទីផ្សារ
- បង្កើតឯកសារឌីជីថល និងឯកសារផ្សេងៗ បញ្ចូលគ្នាជាទម្រង់ឌីជីថលសម្រាប់ប្រើផលិតផល និងសេវាកម្មហិរញ្ញវត្ថុ
- បង្កើតសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់គាំទ្រដល់ធនាគារឌីជីថល
- ចាប់ដៃគូជាមួយស្ថាប័ននានា ដើម្បីភាពរីកចម្រើនរបស់ធនាគារ
- ធ្វើឱ្យសេវាកម្មធនាគារប្រៃសណីយ៍កម្ពុជាក្លាយជាសេវាកម្មដែលអាចទូទាត់កាន់តែទូលំទូលាយអតិថិជន និងដៃគូរអាជីវកម្មក្នុងនិងក្រៅស្រុកពេញចិត្ត នឹងកាន់តែមានទំនុកចិត្តទ្វេរដង។

**ចំពោះសង្គម៖**

- ផ្តល់ជាក្របខ័ណ្ឌសំខាន់នៅក្នុង គោលការណ៍ណែនាំដែលក្នុងនោះធនាគារប្រែសណីយន៍កម្ពុជាអាចអនុវត្តតាមវិធីមួយ ដែលអាចគ្រប់គ្រងរាល់ប្រតិបត្តិការដែលមានផលប៉ះពាល់ដល់សង្គម និងសមាគមន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់។
- អនុលោមទៅតាមច្បាប់សង្គមដែលយើងរស់នៅ និងធ្វើការយ៉ាងសកម្ម ដើម្បីផ្សព្វផ្សាយ វប្បធម៌ដ៏ស្និតស្នាល ដែលមិនមែនតែចំពោះភាគទុននិក កម្មករនិយោជិត អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ គឺថែមទាំងគោរពចំពោះឯកត្តបុគ្គល នៅក្នុងសមាគមន៍របស់យើងទៀតផង។
- ទទួលស្គាល់ថា ការគាំទ្រចំពោះសមាគមន៍មិនមែនគ្រាន់តែជាសីលធម៌ល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអាជីវកម្មមានលក្ខណៈល្អប្រសើរផងដែរពោល គឺមានភាពរឹងមាំ និងរុងរឿង គឺត្រូវបំពេញឱ្យគ្នាទៅវិញទៅមក។
- ទទួលបាននូវការលើកស្ទួយ និងការអភិវឌ្ឍន៍ជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងដោយអនុវត្តន៍ឱ្យបាននូវ និរន្តរភាព និង បង្កើតនូវអត្ថប្រយោជន៍ជាច្រើនជូនដល់ភាគទុននិក កម្មករ និយោជិតព្រមទាំងសមាគមន៍ទាំងអស់។
- សង្គមជាតិក៏ទទួលបាននូវការរីកចម្រើនមួយផ្នែកទៀត រួមទាំងមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យ។
- ទទួលបាននូវគោលការណ៍ សីលធម៌វិជ្ជាជីវ: សង្គម ច្បាប់និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត។
- អាជីវកម្មទាំងអស់ទទួលបាននូវសេវាសុវត្ថិភាពរហ័សទាន់ចិត្តសម្រេចបានទាំងអាជីវកម្មតូច និងធំ។
- ទទួលបាននូវសុកមង្គលនិងស្នាមញញឹម ពីមនុស្សដែលនៅជុំវិញខ្លួនយ៉ាងច្រើន។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ធនាគារប្រៃសណីកម្ពុជា មានចំណុចខ្លាំងដូចជា៖

- ធនាគារប្រៃសណីយ៍កម្ពុជា សម្រេចបាននូវទ្រព្យសកម្មជាង១.១៦ពាន់លានដុល្លារអាមេរិកត្រឹមរយៈពេល ៧ឆ្នាំ តាំងពីឆ្នាំ ២០១៣
- ធនាគារ ប្រៃសណីយ៍កម្ពុជា ជាធនាគារពាណិជ្ជដែលបម្រើសេវាហិរញ្ញវត្ថុ បែបបច្ចេកវិទ្យាឈានមុខគេនៅកម្ពុជា ដែលផ្តល់នូវភាពងាយស្រួល និងមានទំនុកចិត្តខ្ពស់សម្រាប់អតិថិជនគ្រប់កម្រិត ដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណងរីកចម្រើនរបស់ប្រជាពលរដ្ឋកម្ពុជា។
- ធនាគារប្រៃសណីយ៍កម្ពុជាពិតជាមានភាពរីករាយក្នុង ការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ធនាគារដោយធនាគារបានផ្តល់ជូននូវអត្រាខ្ពស់លើគណនីសន្សំ និងរួមផ្សំជាមួយការផ្តល់ជូនដោយឥតគិតថ្លៃលើសេវាធនាគារចល័តដោយផ្តល់មុខងារទំនើបៗជាច្រើន។
- ស្ថាប័នបានរៀបចំរចនាសម្ព័ន្ធបុគ្គល និងការទទួលខុសត្រូវមានលក្ខណៈច្បាស់លាស់ ដែលនាយដ្ឋាននីមួយៗ និងសាខាទាំងអស់បំពេញការងារទៅតាមតួនាទីនិងភារកិច្ចរៀងៗខ្លួន។
- បុគ្គលិកទាំងអស់ សុទ្ធតែមានជំនាញនិងសមត្ថភាពក្នុងការបំពេញការងាររៀងៗខ្លួន។ ស្ថាប័នមានផែនការយុទ្ធសាស្ត្រ និងគោលដៅច្បាស់លាស់ហើយនាយកដ្ឋានទាំងអស់ និងសាខាសុទ្ធតែមានផែនការយុទ្ធសាស្ត្រនិងនីតិវិធីរៀងៗខ្លួន ដែលផែនការទាំងនេះស្របទៅនឹងផែនការរួមរបស់ធនាគារ
- ស្ថាប័នមានផែនការយុទ្ធសាស្ត្រ ក្នុងការផ្តល់សេវាកម្មជូនអតិថិជនជាច្រើនជម្រើស ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ និងងាយស្រួលក្នុងការជ្រើសរើស។
- សាច់ប្រាក់ដែលធនាគារបានបម្រុងសមល្មមទៅនឹងតម្រូវការដាក់ស្តែង ។

## ៤.២ វិភាគលើចំណុចខ្សោយ

ក្រៅពីចំណុចខ្លាំងរបស់ស្ថាប័នក្នុងនោះ ធនាគារក៏មាននូវចំណុចខ្សោយមួយចំនួនក្នុងការអនុវត្តន៍ និងកែតម្រូវផងដែររួមមាន៖

- មិនទាន់មានសាខា ឬទីតាំងប្រតិបត្តិការគ្រប់គ្រាន់ព្រោះបច្ចុប្បន្ន អតិថិជនមានចំនួនច្រើនធ្វើឱ្យមានតម្រូវការគ្រប់ទីកន្លែង។
- ធនាគារបង្កើតឃ្យូពិតមែន ប៉ុន្តែការផ្តល់ឥណទានភាគច្រើន គឺមិនទាន់មានការប្រកួតប្រជែង ហើយមានអត្រាការប្រាក់ខ្ពស់ប្រសិនបើធៀបទៅនឹងធនាគារធំៗដទៃទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសកម្មរបស់ធនាគារ ។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋានៈ

តាមរយៈការសិក្សាស្រាវជ្រាវដោយយកចិត្តទុកដាក់របស់ក្រុមនាងខ្ញុំ នាពេលកន្លងមកលើការរំលឹកទ្រឹស្តី និងការអនុវត្តជាក់ស្តែងដែលទាក់ទងទៅនឹងប្រធានបទសិក្សាស្រាវជ្រាវខាងលើមានដូចជា ការផ្តល់សេវាកម្មធំៗសម្រាប់អតិថិជនទូទៅចំនួនបី គឺសេវាកម្មទទួលប្រាក់បញ្ញើ សេវាកម្មផ្តល់ឥណទាន និងសេវាកម្មទូទាត់ចំណាយផ្សេងៗ។ ចំពោះសេវាកម្មប្រាក់បញ្ញើសន្សំនេះផងដែរ អតិថិជនក៏អាចធ្វើការដក-ដាក់ប្រាក់ដោយខ្លួនឯង នៅតាមបណ្តាលម៉ាស៊ីនATM ដែលនៅក្បែរលោកអ្នកបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

យើងអាចសន្និដ្ឋានបានថា ចំណុចខ្លាំងរបស់ធនាគារប្រៃសណីយ៍កម្ពុជាមួយចំនួនដែលជាបច្ច័យក្នុងការធ្វើឱ្យធនាគារមានភាពរីកចម្រើន និង មានការទទួលស្គាល់ពីសំណាក់អតិថិជន មន្ត្រីរាជការគ្រប់ជាន់ថ្នាក់អាជ្ញាធរមូលដ្ឋាន រដ្ឋាភិបាលនិងពីសំណាក់អ្នកវិនិយោគទុនទាំងក្នុងប្រទេស និង ក្រៅប្រទេសដោយអ្នកទាំងនោះអាចមើលឃើញថា ធនាគារប្រៃសណីយ៍កម្ពុជាពិតជាមានសក្តានុពលពាសពេញពិភពលោក និងជានិរន្ត៍។ ចំពោះបុគ្គលិករបស់ធនាគារប្រៃសណីយ៍កម្ពុជាវិញ យើងឃើញថាការបំពេញការងាររបស់ពួកគាត់គឺពោរពេញ ទៅដោយទេពកោសល្យ ក្រមសីលធម៌ និងវិជ្ជាជីវៈខ្ពស់ ជាពិសេសពួកគាត់មានភាពរួសរាយរាក់ទាក់យ៉ាងល្អចំពោះអតិថិជន ដែលបានមកប្រើសេវាកម្មឬចង់ដឹងព័ត៌មានផ្សេងៗ ពីធនាគារប្រៃសណីយ៍កម្ពុជាទៀតផង។

សរុបសេចក្តីមកឃើញថា ការសិក្សាទៅលើការគ្រប់គ្រងទ្រព្យរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការយល់ដឹងឱ្យកាន់តែច្បាស់អំពីផលិតផល និងការផ្តល់សេវាកម្មនានាដែលធនាគារប្រៃសណីយ៍កម្ពុជាមាន ហើយបានផ្តល់ទៅឱ្យអតិថិជននិងការយល់ដឹងបន្ថែមទៀត ទៅលើការគ្រប់គ្រងទ្រព្យសកម្មរួមជាមួយ និងរបាយការណ៍ហិរញ្ញវត្ថុផងដែរ។

## ៥.២ ការផ្តល់អនុសាសន៍ៈ

តាមរយៈការស្រាវជ្រាវកន្លងមកពីធនាគារប្រៃសណីយ៍កម្ពុជា យើងបានសង្កេតឃើញថាសេវាកម្មរបស់ធនាគារប្រៃសណីយ៍កម្ពុជា កំពុងរីវត្តន៍ និងទទួលបានការគាំទ្រជាច្រើនពីសំណាក់អតិថិជនហើយដើម្បីជម្រុញទីផ្សាររបស់ធនាគារ និងបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា និងបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ។ ដោយលោកអ្នកបានដឹងរួចមកហើយថាធនាគារ ប្រៃសណីយ៍កម្ពុជា បានផ្តល់នូវឥណទានជាច្រើនទៅដល់បងប្អូនដែលជាប្រជាជនកម្ពុជាយើង ដើម្បីបង្កើតនូវមុខជំនួញការជួញដូរ ការវិនិយោគ ការប្រកបអាជីវកម្ម និងឧស្សាហកម្មផ្សេងៗ បង្កើនប្រាក់ចំណូលឱ្យមានការកើនឡើង។

ដោយសារតែមានប្រភពដើមទុនល្អពី ធនាគារ ប្រៃសណីយ៍កម្ពុជាបែបនេះហើយ ទើបធ្វើឱ្យប្រជាជនកម្ពុជាមានជីវភាពកាន់តែប្រសើរឡើង ហើយសេដ្ឋកិច្ចជាតិក៏ឈានទៅរកការអភិវឌ្ឍន៍ផងដែរ។ ប៉ុន្តែទន្ទឹមនឹងនេះធនាគារ ប្រៃសណីយ៍កម្ពុជាក៏មាននូវចំណុចខ្វះខាតមួយចំនួនផងដែរ។ ដូច្នេះហើយ ដើម្បីឱ្យ

ការគ្រប់គ្រងទ្រព្យសកម្ម និងសេវាកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា កាន់តែប្រសើរឡើងថែមទៀតក្រុមនាងខ្ញុំសូមផ្តល់អនុសាសន៍ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- គួរតែបង្កើននិងពង្រីកទីផ្សាររបស់ខ្លួនដោយបង្កើតឱ្យមានសាខា ឬអនុសាខាកាន់តែច្រើនហើយគ្រប់ទីកន្លែងទាំងអស់ ក៏ដូចជាបង្កើតទីតាំងបន្ថែមនៃបញ្ជាដកប្ញជាក់ប្រាក់ (ATM) ដើម្បីកាន់តែងាយស្រួលដល់អតិថិជន និងបង្កើនគុណភាពសេវាកម្មជាផ្នាក់ទាញអតិថិជន ក្នុងការប្រើប្រាស់សេវារបស់ខ្លួនក្នុងការប្រកួតប្រជែងផ្នែកទីផ្សារជាមួយធនាគារដទៃទៀតផងដែរ។
- គួរតែរិះរកវិធីសាស្ត្រថ្មីៗមួយចំនួនដើម្បីធ្វើឱ្យការផ្តល់ឥណទានរបស់ខ្លួន មានការប្រកួតប្រជែងខ្ពស់ជាមួយនឹងធនាគារដទៃ និងគិតគូរឱ្យបានល្អិតល្អន់ចំពោះអត្រាការប្រាក់ដែលផ្តល់ជូនអតិថិជន។

# ឯកសារយោង

# ឯកសារយោង


- វិទ្យាស្ថានវ៉ាន់ដា រូបិយវត្ថុ និងធនាគារ ភាគ១ បោះពុម្ពលើកទី៥ ឆ្នាំ២០១៩ មាន៥៨ ទំព័រ ចាប់ពីទំព័រទី ៥១ ដល់ ទំព័រទី ៥៥
- វិទ្យាស្ថាន វ៉ាន់ដា សេចក្ដីផ្ដើមនៃនីតិ ភាគ១ បោះពុម្ពលើកទី៩ ឆ្នាំ ២០២២ មាន១០១ទំព័រ ក្នុងទំព័រទី៤
- វិទ្យាស្ថាន វ៉ាន់ដា (២០១៩) INTRODUCTION TO LAW ទំព័រទី ១៥
- ដកស្រង់ចេញពីសេចក្ដីផ្ដើមនៃនីតិខ្មែររៀបរៀងដោយ៖ កៅ មុយថង, មុនី វីរៈ, វ៉ាន់ ច័ន្ទតារា ទំព័រទី ១៥
- វិទ្យាស្ថាន វ៉ាន់ដា (សេចក្ដីផ្ដើមនៃនីតិ ២០១៩) ទំព័រទី ១៦
- ដកស្រង់ចេញពីសេចក្ដីផ្ដើមនៃនីតិខ្មែររៀបរៀងដោយ៖ កៅ មុយថង, មុនី វីរៈ, វ៉ាន់ ច័ន្ទតារា ទំព័រទី ១៧
- បណ្ណាល័យរបស់វិទ្យាស្ថានវ៉ាន់ដា
- ទិន្នន័យស្រាវជ្រាវផ្សេងៗ ដូចជា៖
- សៀវភៅពុម្ពនៃវិទ្យាស្ថាន វ៉ាន់ដា (2017) PRICIPLE OF MANAGEMENT
- https://www.cambodiapostbank.com.kh/
- https://m.facebook.com/858652100918355/photos/a.930019690448262/1674677989315758/?type=3
- https://hi-in.facebook.com/MeMongPage/posts/1558024454374090/
- https://mathnmoney.blogspot.com/2018/09/active-asset.html
- https://km.swewe.net/word_show.htm
- https://mathnmoney.blogspot.com/2018/09/active-asset.html
- mathandmoney.com: តើអ្វីទៅជា "ទ្រព្យសកម្ម ឬActive Asset"? (mathnmoney.blogspot.com)
- https://khemsarith.wordpress.com/2016/Abank-asset/
- https://thmeythmey.com/?page=detail&id=76035
- https://khemsarith.wordpress.com/
- https://web.facebook.com/100064228896213/posts/175682297801762/
- https://naraumelaw.files.wordpress.com/2013/09/sana-all-sorya-ume.pdf
- https://propertyarea.asia/archives/79061
- https://khemsarith.wordpress.com/2016/the-roles-of-banks/
- https://m.facebook.com/182088021967747/posts/878290655680810/
- https://m.facebook.com/permalink.php?story_fbid=1563902050413910&id=1482208281916621
- https://m.facebook.com/permalink.php?story_fbid=565184501339378&id=345437756647388
- https://clubniset.wordpress.com/2011/05/31/
- https://web.facebook.com/HeartBookCambodia/posts/5646929262067994/?locale=hi_IN
- http://sabeaninfo.blogspot.com/2012/01/blog-post.html?m=1
- https://www.khsearch.com/qna/24822

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ

## ភាគទុនិក







### 50% កាណាឌីយ៉ា អ៊ិនវេសមិន ហូលឌីង ភីអិលស៊ី

កាណាឌីយ៉ា អ៊ិនវេសមិនហូលឌីង ជាក្រុមហ៊ុនវិនិយោគលើវិស័យហិរញ្ញវត្ថុដ៏ធំ និងគួរឱ្យទុកចិត្តមួយនៅក្នុងប្រទេសកម្ពុជា។ កាណាឌីយ៉ាអ៊ិនវេសមិនហូលឌីង មានទ្រព្យសកម្មសរុបជាង ៧,២ពាន់លានដុល្លារអាមេរិក គិតត្រឹមចុងឆ្នាំ២០២០។ កាណាឌីយ៉ា អ៊ិនវេសមិនហូលឌីង ស្វែងរកប្រាក់ចំណូលតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ និងសាខា (៨ ស្ថាប័ន) តាមរយៈការផ្តល់នូវសេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាធនាគារពាណិជ្ជ (សាជីវកម្ម សហគ្រាសខ្នាតតូច និងមធ្យម និងអតិថិជន) មីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រងអាយុជីវិត ធានារ៉ាប់រងទូទៅ និងទីផ្សារមូលបត្រក្នុងប្រទេសកម្ពុជា។ កាណាឌីយ៉ា អ៊ិនវេសមិនហូលឌីង មានបទពិសោធន៍នៅក្នុងទីផ្សារកម្ពុជា និងធ្វើប្រតិបត្តិការដោយមានវិន័យ និងប្រកបដោយប្រសិទ្ធភាព។

### 45% ហ្វូឡឺតុនហ្វាយណាន់ស្យលខាប់ពីតាល់ ភីធីអ៊ី

**បុត្រសម្ព័ន្ធរបស់ ហ្វូឡឺតុន ហ្វាយណាន់ស្យលហ៊ូលឌីង**

ហ្វូឡឺតុនហ្វាយណាន់ស្យល ខាប់ភីតាល់ ភីធីអ៊ី បានវិនិយោគ និងធ្វើប្រតិបត្តិការជាស្ថាប័នហិរញ្ញវត្ថុនៅក្នុងទីផ្សារ ដែលកំពុងរីកចម្រើនដោយផ្តោតលើការបម្រើសេវាកម្មដល់សហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មទីផ្សារចម្រុះតាមរយៈការអភិវឌ្ឍន៍ និងប្រតិបត្តិនូវខ្នាតគំរូអាជីវកម្ម ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងល្អជាច់គេ។

### 5% ប្រៃសណីយ៍កម្ពុជា

នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា

ប្រៃសណីយ៍កម្ពុជា គឺជាអង្គភាពស្វយ័តដែលស្ថិតនៅក្រោមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ប្រៃសណីយ៍ និងប្រព័ន្ធទូរគមនាគមន៍កម្ពុជា។

ប្រៃសណីយ៍កម្ពុជាទទួលបានសិទ្ធិអំណាចពិសេសដែលផ្តល់ដោយរដ្ឋាភិបាល ក្នុងការជួយគាំទ្រនូវគោលបំណង បេសកកម្ម ចក្ខុវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- 2015-2017 ស្តង់ដារគណនេយ្យអន្តរជាតិ នៃកម្ពុជា
- 2018-2020 ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា

# សមិទ្ធផលសម្រេចបាន

### រួមបញ្ចូលជាមួយគ្រឹះស្ថាន **ហ្វូណាន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី** ដែលជាបុត្រសម្ព័ន្ធរបស់ធនាគារ

**សមតុល្យឥណទាន**
**$692 លាន**




**ប្រាក់ចំណូលសរុប**
**$96 លាន**




**ទ្រព្យសកម្មសរុប**
**$1.06 ពាន់លាន**




**ប្រាក់ចំណេញសរុប**
**$11 លាន**




- 2015-2017: ស្តង់ដារគណនេយ្យអន្តរជាតិ នៃកម្ពុជា
- 2018-2020: ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា

## ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
## និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### របាយការណ៍ហិរញ្ញវត្ថុរួម
### និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
### ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020
### និង
### របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីធនាគារ

| | | |
|---|---|---|
| ធនាគារ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 1794 ម/2013 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 265-269 ផ្លូវព្រះអង្គឌួង<br>សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | កាណាឌីយ៉ា អ៊ិនវេសមេន ហូលឌីង ក.អ<br>Fullerton Financial Capital Pte. Ltd. ("Fullerton")<br>ប្រៃសណីយ៍កម្ពុជា ប.ក | |
| ក្រុមប្រឹក្សាភិបាល | អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Yeo Hong Ping | អនុប្រធានក្រុមប្រឹក្សាភិបាល |
| | លោក រស់ ភីរុណ | អភិបាល |
| | លោកស្រីវេជ្ជបណ្ឌិត Pung Carolyne | អភិបាល |
| | លោក Teo Meng Poh Philip | អភិបាលមិនប្រតិបត្តិ |
| | លោក Neo Poh Kiat | អភិបាលឯករាជ្យមិនប្រតិបត្តិ |
| | លោក Giang Sovann | អភិបាលឯករាជ្យមិនប្រតិបត្តិ |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE

ភាគ១




## រូបិយវត្ថុ និងធនាគារ
## MONEY AND BANKING

Scanned with CamScanner

បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE

ភាគ២




# រូបិយវត្ថុ និងធនាគារ
# MONEY AND BANKING

Scanned with CamScanner

បោះពុម្ពលើកទី៤(២០១៧) សម្រាប់ប្រើផ្ទៃក្នុង